ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកសិកម្ម

គម្រោងជំរុញផលិតកម្មស្បៀង

# ខ្សែសង្វាក់ផលិតកម្ម
# ដំណាំស្វាយចន្ទីនៅកម្ពុជា



## កត្តាប្រឈមក្នុងផលិតកម្ម

គម្រោងជំរុញផលិតកម្មស្បៀង

Boosting Food Production Program

រៀបចំដោយៈ ការិយាល័យគ្រប់គ្រងគម្រោង (PMO)

ឧបត្ថម្ភៈ រាជរដ្ឋាភិបាលកម្ពុជា

ឆ្នាំ២០១៧

# សង្ខេបរបាយការណ៍

ការសិក្សាពីខ្សែសង្វាក់ផលិតកម្មដំណាំស្វាយចន្ទីនៅប្រទេសកម្ពុជា បានធ្វើឡើងក្នុងខេត្តចំនួនបីគឺ កំពង់ចាម កំពង់ធំ និងរតនគិរី។ កសិករដាំស្វាយចន្ទី ២៥០គ្រួសារដែលដាំដុះស្វាយចន្ទី និងធ្លាប់ប្រមូលផលចន្ទីចាប់ពីម្តងឡើងទៅត្រូវសំភាសន៍។ ការសិក្សានេះមានគោលបំណង ១) ដើម្បីកំណត់ពីបញ្ហាប្រឈមនានា របស់អ្នកពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់ផលិតកម្មស្វាយចន្ទី ២) ដើម្បីស្វែងរកនូវដំណោះស្រាយដែលសមស្របក្នុងការធានាបាននូវផលប្រយោជន៍របស់អ្នកពាក់ព័ន្ធទាំងអស់ និង ៣) ដើម្បីកំណត់ពីតម្រូវការបច្ចេកទេសរបស់អ្នកពាក់ព័ន្ធក្នុងខ្សែសង្វាក់ផលិតកម្ម ដើម្បីឱ្យស្ថាប័នជំនាញអាចជួយអន្តរាគមន៍បានប្រកបដោយប្រសិទ្ធភាព។ ការសិក្សាបានបង្ហាញពីលទ្ធផលសំខាន់ៗដូចខាងក្រោមៈ

កសិករកំពុងប្រើពូជស្វាយចន្ទីប្រភេទពូជអឹម០៩ ពូជអឹម២១ ពូជអឹម២៣ និងពូជស្វាយចន្ទីប្រពៃណីខ្មែរ។ និន្នាការប្តូរពីចម្ការពូជស្វាយចន្ទីប្រពៃណីខ្មែរទៅដាំពូជអឹម កាន់តែកើនឡើង ដោយសារពូជប្រភេទអឹម មានសំបកស្តើងនិងសាច់គ្រាប់ធំ។ ទិន្នផលជាមធ្យម គឺ ៧៥០គក ក្នុង១ហត ប៉ុន្តែមានកសិករមួយចំនួនទទួលបានទិន្នផលរហូតដល់ ៤.៥០០គក ក្នុង១ហតដែរ។

ទីផ្សារគ្រាប់ស្វាយចន្ទីនៅតំបន់ដែលបានសិក្សា គឺពឹងលើទីផ្សារប្រទេសវៀតណាម។ គ្រាប់ស្វាយចន្ទីស្រស់ត្រូវបានប្រមូលទិញដោយបណ្តាញឈ្មួញ និងអ្នកនាំចេញ ឬ សែឡូទៅប្រទេសវៀតណាម។

តម្លៃគ្រាប់ស្វាយចន្ទីស្រស់ខ្ពស់បំផុតនៅដើមរដូវ គឺ ៨.៥០០រៀលក្នុង១គក និងតម្លៃចុងរដូវ គឺ ៤.០០០រៀលក្នុង១គក។ ជាមធ្យម កសិករអាចលក់បាននៅរដូវសម្បូណ៌គ្រាប់ស្វាយចន្ទីស្រស់ គឺ ៦.០០០រៀលក្នុង១គកនៅឆ្នាំ ២០១៧ ដែលជាតម្លៃកសិកររំពឹងទុកជារៀងរាល់ឆ្នាំ។

កសិករអាចទទួលបានប្រាក់ចំណូលដុលពីការលក់ស្វាយចន្ទីប្រហែល ៤,៣ លានរៀល/ហត និងចំណាយប្រហែល ៤៥ ម៉ឺនរៀល/ហត។ ដូច្នេះ កសិករអាចរកចំណេញសុទ្ធ ក្នុងមួយឆ្នាំៗ ប្រហែល ៣,៩ លានរៀល/ហត។

ក្នុងចំណោមធាតុចូលកសិកម្មទាំងអស់ ចំណាយលើថ្នាំពុលគីមីសំលាប់សត្វល្អិតមានទំហំជាមធ្យម ១៥% នៃខ្ទង់ចំណាយសរុប ឬបរិមាណ ២២០.០០០រៀល/ហត ហើយវាមិនអាចកំណត់បានព្រោះវាអាស្រ័យទៅលើកម្រិតបំផ្លាញរបស់សត្វល្អិត ជាពិសេស សត្វល្អិតថ្មី ដែលកសិករស្គាល់ថាជា មូសតែ។ ក្នុងកម្រិតបំផ្លាញខ្លាំង ចំណាយលើថ្នាំកំចាត់សត្វល្អិតឡើងរហូតដល់ ១ ទៅ ២ លានរៀល/ហត ។

ម.ឯ.ឯ.ក AIDOC
Code: 118-013
Date:
Donated by:

ដើម្បីរួមចំណែកទៅនឹងដំណោះស្រាយដូចបានលើកឡើង នៅក្នុងគោលបំណងនៃការសិក្សាខាងលើ ការសម្របសម្រួល និងគោលនយោបាយគាំទ្រផលិតកម្មស្វាយចន្ទី គួរគប្បីផ្តោតលើចំណុចខាងក្រោម៖

- ជម្រុញលើកទឹកចិត្តក្រុមហ៊ុនឯកជនវិនិយោគលើសិប្បកម្ម និងរោងចក្រកែច្នៃគ្រាប់ស្វាយចន្ទីក្នុងស្រុកថែមទៀត
- ស្ថាប័នជំនាញត្រូវបន្តពង្រឹងការស្រាវជ្រាវនិងផ្សព្វផ្សាយលើពូជថ្មីៗ ដែលកសិករទទួលយកតាមតម្រូវការទីផ្សារក្រៅប្រទេស
- ស្ថាប័នជំនាញគួរស្វះស្វែងជួយកសិករដាំស្វាយចន្ទីជាបន្ទាន់ក្នុងការទប់ស្កាត់ការបំផ្លាញពីសត្វល្អិតប្រភេទថ្មី គឺ មូសតែ ដែលទើបរាតត្បាតក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ។

# មាតិកា


សង្ខេបរបាយការណ៍

មាតិកា

១. សេចក្តីផ្តើម ........ 1

១.១ ប្រវត្តិនៃគម្រោង ........ 1

១.២ គោលបំណង ........ 2

២. វិធីសាស្ត្រ ........ 2

២.១ ទីកន្លែងនៃការសិក្សា ........ 2

២.២ ទំហំនៃការសិក្សា ........ 3

២.៣ ការជ្រើសរើសសំណាក ........ 3

២.៤ ការប្រមូលទិន្នន័យ ........ 3

២.៥ ការវិភាគទិន្នន័យ ........ 4

៣. សំយោគឯកសារ ........ 4

៣.១ ប្រវត្តិដំណាំស្វាយចន្ទី ........ 4

៣.២ លក្ខណៈទូទៅនៃដំណាំស្វាយចន្ទី ........ 5

៣.៣ ការប្រើប្រាស់ផលិតផលស្វាយចន្ទី ........ 6

៣.៤ ទំហំផលិតកម្ម និងតម្រូវការគ្រាប់ស្វាយចន្ទីលើសកលលោក ........ 7

៣.៥ ស្ថានភាពទូទៅនៃដំណាំស្វាយចន្ទីនៅប្រទេសកម្ពុជា ........ 9

៣.៥.១ ផ្ទៃដីដាំដុះដំណាំស្វាយចន្ទីនៅកម្ពុជា ........ 9

៣.៥.២ ផលិតកម្ម និងតម្រូវការស្វាយចន្ទីក្នុងប្រទេសកម្ពុជា ........ 10

៤. លទ្ធផល និងការពិភាក្សា ........ 11

៤.១ ព័ត៌មានទូទៅរបស់អ្នកឆ្លើយតបក្នុងការសិក្សា ........ 11

៤.២ ការដាំដុះ និងប្រមូលផល ........ 13

៤.២.១ ប្រតិទិនដំណាំស្វាយចន្ទី ........ 13

៤.២.២ ពូជស្វាយចន្ទី ........ 14

៤.៣ និន្នាការនៃការដាំដំណាំស្វាយចន្ទី ........ 16

៤.៤ ទីផ្សារ គ្រាប់ស្វាយចន្ទី ........ 17

៤.៤.១ គុណភាពគ្រាប់ស្វាយចន្ទី ........ 17

៤.៤.២ តម្លៃគ្រាប់ស្វាយចន្ទី ........ 18

៤.៥ ខ្សែសង្វាក់ផលិតកម្មស្វាយចន្ទី ........ 20
៤.៥.១ អ្នកផ្គត់ផ្គង់ធាតុចូល ........ 20
៤.៥.២ អ្នកផលិត ........ 22
៤.៥.៣ អ្នកទិញ និងនាំចេញ ........ 24
៤.៦ ការប្រឈមចំពោះដំណាំស្វាយចន្ទី ........ 27
៤.៦.១ ការប្រឈមដោយការប្រើពូជថ្មី ........ 27
៤.៦.២ ការប្រឈមដោយសត្វល្អិតថ្មី ........ 28
៤.៦.៣ សត្វល្អិត មូសតែ ........ 29
៤.៦.៤ បញ្ហាបាត់បង់ដីជាតិដី ........ 31
៤.៧ ការពិភាក្សា ........ 32
៤.៧.១ បច្ចេកទេសដាំពូជថ្មី ........ 32
៤.៧.២ បញ្ហាសត្វល្អិតបំផ្លាញ និង មូសតែ ........ 33
៤.៧.៣ បញ្ហាតម្លៃទីផ្សារគ្រាប់ស្វាយចន្ទី ........ 34
៥. សន្និដ្ឋាន និងអនុសាសន៍ ........ 35
ឯកសារយោង ........ 39
បញ្ជីសំណួរសម្រាប់សំភាសន៍គ្រួសារ ........ 41
បញ្ជីសំណួរសម្រាប់ក្រុមពិភាក្សា ........ 49

# បញ្ជីតារាង


តារាងទី ១៖ ព័ត៌មានពីកសិករនិងគ្រួសារកសិករដាំដំណាំស្វាយចន្ទី .......................................... 11

តារាងទី ២៖ ការតាំងទីលំនៅថ្មីនៃគ្រួសារកសិករដាំដំណាំស្វាយចន្ទី .......................................... 12

តារាងទី ៣៖ ប្រតិទិនពីការដាំ និងការប្រមូលផលនៃដំណាំស្វាយចន្ទី .......................................... 13

តារាងទី ៤៖ ពូជស្វាយចន្ទីដែលដាំដោយកសិករក្នុងតំបន់សិក្សា .......................................... 14

តារាងទី ៥៖ មូលហេតុនៃការជ្រើសរើសពូជស្វាយចន្ទីដែលដាំ (ចំនួនគ្រួសារ ២៥០នាក់)........... 15

តារាងទី ៦៖ ប្រភេទពូជស្វាយចន្ទីដែលដាំដោយកសិករក្នុងតំបន់សិក្សា.......................................... 15

តារាងទី ៧៖ ការតាំងចិត្តដាំដំណាំស្វាយចន្ទីទៅអនាគត .......................................... 16

តារាងទី ៨៖ ការផ្តល់យោបល់ពីនិន្នាការទិន្នផលស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់) ............... 17

តារាងទី ៩៖ តម្លៃគ្រាប់ស្វាយចន្ទីស្រស់តាមចម្ការ ឆ្នាំ ២០១៦ - ២០១៧ (ចំនួនគ្រួសារ ២៥០នាក់).. 19

តារាងទី ១០៖ តម្លៃគ្រាប់ស្វាយចន្ទីស្រស់លក់ទូទៅឆ្នាំ ២០១៤ - ២០១៦ (ចំនួនគ្រួសារ ២៥០នាក់) 19

តារាងទី ១១៖ ជាតុចូល និងសមាមាត្រចំណាយនៃដំណាំស្វាយចន្ទីក្នុង (រៀល/ហត) ................ 21

តារាងទី ១២៖ ផ្ទៃដីដាំចម្ការស្វាយចន្ទីដែលបានដាំឬកំពុងប្រមូលផល (ចំនួនគ្រួសារ ២៥០នាក់).23

តារាងទី ១៣៖ កម្លាំងពលកម្ម និងបទពិសោធន៍គ្រួសារដាំស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់) ...23

តារាងទី ១៤៖ ទិន្នផលនិងចំណូលពីការដាំស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់)......................24

តារាងទី ១៥៖ លក្ខណៈរបស់អ្នកពាក់ព័ន្ធក្នុងខ្សែសង្វាក់គ្រាប់ស្វាយចន្ទីស្រស់...........................25

តារាងទី ១៦៖ ទំហំនៃការជួបប្រទះបញ្ហារបស់ស្វាយចន្ទីតាមពូជ (ចំនួនគ្រួសារ ២៥០នាក់)........29

តារាងទី ១៧៖ កត្តាប្រឈមផ្សេងៗធៀបនឹងការបំផ្លាញដោយសត្វល្អិត (ចំនួនគ្រួសារ ២៥០នាក់) 32

# បញ្ជីក្រាហ្វិក


ក្រាភិកទី ១៖ គំនូសបំព្រួញនៃដំណាំស្វាយចន្ទី (ប្រភពៈ Wikiperdia, 2011) ........ 5

ក្រាភិកទី ២៖ គំនូសបំព្រួញពីដំណើរការពាណិជ្ជកម្មគ្រាប់ស្វាយចន្ទីដែលកែច្នៃ និងមិនទាន់កែច្នៃ នៅលើពិភពលោកក្នុងឆ្នាំ ២០១១ (ប្រភពៈ Red River Food, Inc, 2011) ........ 8

ក្រាភិកទី ៣៖ ខេត្តដែលមានផ្ទៃដីដាំដុះស្វាយចន្ទីច្រើនជាងគេទាំង ៧ នៅកម្ពុជា (ប្រភពៈ NIS, 2015) ........ 9

ក្រាហ្វិកទី ៤៖ ការផ្តល់យោបល់ពីនិន្នាការទិន្នផលស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់) ........ 16

ក្រាហ្វិកទី ៥៖ ខ្សែសង្វាក់នៃការផលិតនិងទិញលក់គ្រាប់ស្វាយចន្ទីស្រស់នៅខេត្តកំពង់ធំ និងកំពង់ចាម ........ 26

ក្រាហ្វិកទី ៦៖ ខ្សែសង្វាក់នៃការផលិតនិងទិញលក់គ្រាប់ស្វាយចន្ទីស្រស់នៅខេត្តរតនគិរី ........ 26

ក្រាហ្វិកទី ៧៖ កត្តាប្រឈមលើដំណាំស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់) ........ 28

ក្រាភិកទី ១៖ គំនូសបំព្រួញនៃដំណាំស្វាយចន្ទី (ប្រភពៈ Wikiperdia, 2011) ........ 5

ក្រាភិកទី ២៖ គំនូសបំព្រួញពីដំណើរការពាណិជ្ជកម្មគ្រាប់ស្វាយចន្ទីដែលកែច្នៃ និងមិនទាន់កែច្នៃនៅលើពិភពលោកក្នុងឆ្នាំ ២០១១ (ប្រភពៈ Red River Food, Inc, 2011) ........ 8

ក្រាភិកទី ៣៖ ខេត្តដែលមានផ្ទៃដីដាំដុះស្វាយចន្ទីច្រើនជាងគេទាំង ៧ នៅកម្ពុជា ........ 9

(ប្រភពៈ NIS, 2015) ........ 9

ក្រាហ្វិកទី ៤៖ ការផ្តល់យោបល់ពីនិន្នាការទិន្នផលស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់) ........ 16

ក្រាហ្វិកទី ៥៖ ខ្សែសង្វាក់នៃការផលិតនិងទិញលក់គ្រាប់ស្វាយចន្ទីស្រស់នៅខេត្តកំពង់ធំ និងកំពង់ចាម ........ 26

ក្រាហ្វិកទី ៦៖ ខ្សែសង្វាក់នៃការផលិតនិងទិញលក់គ្រាប់ស្វាយចន្ទីស្រស់នៅខេត្តរតនគិរី ........ 26

ក្រាហ្វិកទី ៧៖ កត្តាប្រឈមលើដំណាំស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់) ........ 28


# បញ្ជីរូបភាព


រូបភាពទី ១៖ ផែនទីបង្ហាញពីទីតាំងសិក្សាក្នុងខេត្តទាំងបី ........ 2

រូបភាពទី ២៖ ដើមស្វាយចន្ទីដែលមានទំហំធំជាងគេលើពិភពលោក (Wikiperdia, 2011) ........ 6

រូបភាពទី ៣៖ គុណភាពនៃគ្រាប់ស្វាយចន្ទី ........ 17

រូបភាពទី ៤៖ មូលតែរាតត្បាតនៅដំណាំស្វាយចន្ទី និងដំណាំតែនៅប្រទេសឥណ្ឌា ........ 30

រូបភាពទី ៥៖ មូសតែ ដែលបំផ្លាញត្រួយស្វាយចន្ទី ........ 30

## ១. សេចក្តីផ្តើម

### ១.១ ប្រវត្តិនៃគម្រោង

វិស័យកសិកម្មមិនត្រឹមតែបានចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិតែប៉ុណ្ណោះទេ តែថែមទាំងបានចូលរួមចំណែកយ៉ាងធំធេងដល់សង្គមជាតិទាំងមូល ក៏ដូចជាការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជាផងដែរ។ ក្រៅពីស្រូវ និងដំណាំប្រចាំរដូវកាល ដំណាំផ្សេងៗទៀតបានកំពុងតែមានការរីកលូតលាស់ និងត្រូវបានពង្រីកការដាំដុះរួមទាំងដំណាំស្វាយចន្ទីផងដែរ។ ស្វាយចន្ទី មានសក្តានុពលខ្ពស់ សម្រាប់ធ្វើការដាំដុះ បង្កើតការងារ និងចូលរួមចំណែកក្នុងការផ្តល់ប្រាក់ចំណូលជូនប្រជាពលរដ្ឋ។

នៅកម្ពុជា ដំណាំស្វាយចន្ទី ត្រូវបានចាត់ជាដំណាំអចិន្ត្រៃយ៍។ ផ្ទៃដីដាំដុះដំណាំនេះ ត្រូវបានពង្រីកពីមួយឆ្នាំទៅមួយឆ្នាំនៅតាមបណ្តាខេត្តមួយចំនួន ដោយនៅក្នុងឆ្នាំ ២០១២ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ដែលមានត្រឹមតែ ១៩៣.៧៥១ ហិកតា[1] បានកើនឡើងដល់ ២៣៨.៧៨០ ហិកតា នាឆ្នាំ ២០១៦[2] ឬមានការកើនឡើងប្រមាណជាង ២៣ភាគរយ ក្នុងរយៈពេល៥ឆ្នាំ ។

ទោះបីជាការដាំដុះស្វាយចន្ទីមានការរីកចំរើនគួរឱ្យកត់សំគាល់ ក៏បញ្ហាប្រឈមមួយចំនួនបានកើតមានឡើងដល់អ្នកពាក់ព័ន្ធទាំងអស់ក្នុងខ្សែសង្វាក់ផលិតកម្ម ដែលទាមទារនូវការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ រាល់បញ្ហាប្រឈមទាំងឡាយដែលកើតមានឡើង ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ ក្នុងការឈានទៅរកការដាំដុះស្វាយចន្ទីប្រកបដោយនិរន្តរភាព ក៏ដូចជាការលើកស្ទួយកម្រិតជីវភាពរបស់កសិករ អ្នកពាក់ព័ន្ធក្នុងខ្សែសង្វាក់ផលិតកម្មនិងចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ទស្សនៈស្តីពីខ្សែតម្លៃនៅក្នុងខ្សែសង្វាក់ផលិតកម្មកសិកម្ម ត្រូវបានប្រើប្រាស់តាំងពីយូរយារណាស់មកហើយ ដែលចាប់ផ្តើមដំបូងដោយអ្នកដែលធ្វើការពាក់ព័ន្ធជាមួយការអភិវឌ្ឍកសិកម្មនៅតាមបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍។ ទោះជាគ្មាននិយមន័យដែលឯកភាពគ្នាជាសាកលមួយក៏ដោយ តែវាសំដៅទៅលើទំនិញ និងសេវាកម្មទាំងមូលដែលចាំបាច់សម្រាប់បញ្ជូនផលិតផលកសិកម្មពីស្រែ/ចម្ការរហូតដល់អតិថិជនចុងក្រោយ ឬអ្នកប្រើប្រាស់។

[1] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០១៣. របាយការណ៍បូកសរុបការងារ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ ២០១១-២០១២ និងទិសដៅការងារសម្រាប់ឆ្នាំ២០១២-២០១៣

[2] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០១៧. របាយការណ៍បូកសរុបការងារ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ ២០១៥-២០១៦ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៦-២០១៧

### ១.២ គោលបំណង

- ដើម្បីកំណត់ពីបញ្ហាប្រឈមនានា របស់អ្នកពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់ផលិតកម្មស្វាយចន្ទី ដើម្បីស្វែងរកនូវដំណោះស្រាយដែលសមស្រប ក្នុងការធានាបាននូវផលប្រយោជន៍របស់អ្នកពាក់ព័ន្ធទាំងអស់។
- កំណត់ពីតម្រូវការបច្ចេកទេសរបស់អ្នកពាក់ព័ន្ធក្នុងខ្សែសង្វាក់ផលិតកម្ម ដើម្បីឱ្យស្ថាប័នជំនាញ អាចជួយអន្តរាគមន៍បានប្រកបដោយប្រសិទ្ធភាព។

## ២. វិធីសាស្ត្រ

### ២.១ ទីកន្លែងនៃការសិក្សា

ការសិក្សាត្រូវបានធ្វើឡើងនៅក្នុងស្រុកចំនួន ៥ នៅក្នុងខេត្តចំនួន ៤ ដែលមានឃុំសរុបចំនួន១០ ដូចបង្ហាញជូននៅក្នុងរូបភាពទី១ខាងក្រោម។

***រូបភាពទី១៖*** *ផែនទីបង្ហាញពីទីតាំងសិក្សាក្នុងខេត្តទាំងបី*



## ២.២ ទំហំនៃការសិក្សា

ស្វាយចន្ទីត្រូវបានដាំនៅតាមបណ្តាខេត្តជាច្រើន នៃព្រះរាជាណាចក្រកម្ពុជា ទោះជាយ៉ាងណា ការសិក្សានេះធ្វើឡើងតែក្នុងខេត្តចំនួន៣ដែលបានជ្រើសរើសតែប៉ុណ្ណោះ។ ខេត្តទាំងនេះរួមមាន ខេត្តកំពង់ចាម រតនគិរី និងខេត្តកំពង់ធំ។ ចំណែកឯឈ្មួញកណ្តាល និងអ្នកប្រើប្រាស់ចុងក្រោយ ដែលមិនស្ថិតនៅក្នុងខេត្តដូចបានរៀបរាប់ខាងលើនេះ និងមិនត្រូវបានធ្វើការសំភាសន៍ឬសិក្សានោះទេ។

## ២.៣ ការជ្រើសរើសសំណាក

ការសិក្សាធ្វើឡើងក្នុងខេត្ត កំពង់ចាម រតនគិរី និងខេត្តកំពង់ធំ។ ដោយអាស្រ័យ ទៅតាមពេលវេលានោះ អ្នកដាំស្វាយចន្ទី២៥០គ្រួសារ (ប្រមាណ៨៤គ្រួសារក្នុងមួយខេត្ត) ត្រូវបានជ្រើសរើសដើម្បីសំភាសន៍។ ជាងនេះទៀត គ្រួសារដែលដាំដុះស្វាយចន្ទី និងធ្លាប់ប្រមូលផលស្វាយចន្ទី និងត្រូវធ្វើការសំភាសន៍។ ដោយកសិករអាចមានភាពខុសគ្នាដោយសារទំហំផ្ទៃដីដាំដុះ នោះកសិករខ្នាតតូច មធ្យម និងធំ ត្រូវបានជ្រើសរើសដើម្បីធ្វើសំភាសន៍ឱ្យមានសមាមាត្រគ្នា ដែលមានន័យថា ចំនួនសំណាកដែលត្រូវជ្រើសរើសនិងគ្របដណ្តប់ទាំងកសិករខ្នាតតូច មធ្យម និងធំ ឱ្យមានភាពស្មើគ្នា។ ការសំភាសន៍កសិករផ្តោតសំខាន់ទៅលើផលិតកម្មស្វាយចន្ទី និងបញ្ហាដែលគាត់ជួបប្រទះ ក៏ដូចជាសំណូមពររបស់កសិករផងដែរ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលគាត់ជួបប្រទះក្នុងការដាំដុះស្វាយចន្ទី។ កសិករក៏ត្រូវសាកសួរផងដែរអំពីព័ត៌មានរបស់ឈ្មួញកណ្តាលដែលប្រមូលទិញនៅក្នុងខេត្តផងដែរ ដើម្បីឱ្យអ្នកសំភាសន៍តាមទៅសំភាសន៍។

បន្ទាប់ពីបានព័ត៌មានពីកសិករ នោះឈ្មួញកណ្តាល និងអ្នកប្រើប្រាស់ចុងក្រោយត្រូវបានសំភាសន៍។ ការសំភាសន៍នេះផ្តោតជាសំខាន់ទៅលើបញ្ហាប្រឈមដែលគាត់បានជួបប្រទះ និងសំណូមពរដែលពាក់ព័ន្ធជាមួយឈ្មួញកណ្តាលឬអ្នកប្រើប្រាស់ចុងក្រោយ។

## ២.៤ ការប្រមូលទិន្នន័យ

បញ្ជីសំណួរត្រូវបានរៀបចំសម្រាប់សំភាសន៍ជាមួយកសិករ។ សំណួរទាំងនោះត្រូវបានចែកចេញ ជាបីផ្នែកសំខាន់គឺ ព័ត៌មានស្តីពីកសិករ ផលិតកម្មស្វាយចន្ទី និងព័ត៌មានរបស់ឈ្មួញកណ្តាល រួមទាំងសំណូមពររបស់កសិករផងដែរ។

តាមរយៈព័ត៌មានដែលទទួលបានមកពីកសិករស្តីពីឈ្មួញកណ្តាល ឬអ្នកប្រើប្រាស់ចុងក្រោយ ក្រុមការងារសិក្សាស្រាវជ្រាវ ត្រូវតាមសំភាសន៍ជាមួយអ្នកពាក់ព័ន្ធទាំងនោះតាមរយៈបញ្ជីសំណួរគន្លឹះមួយចំនួនដែលបានរៀបចំជាស្រេចដោយប្រធានក្រុមដឹកនាំការសិក្សា។



ការពិភាក្សាជាក្រុម ត្រូវបានធ្វើឡើងដោយអញ្ជើញអ្នកពាក់ព័ន្ធប្រមាណ ១០នាក់ ក្នុងមួយក្រុម នៅក្នុងខ្សែសង្វាក់ផលិតកម្មដើម្បីពិភាក្សា។ សមាជិកក្រុមពិភាក្សា រួមមានកសិករ ឈ្មួញកណ្តាល និងអ្នកប្រើប្រាស់ចុងក្រោយ ដោយអ្នកចូលរួមជាស្ត្រីត្រូវបានលើកទឹកចិត្តដើម្បីចូលរួមពិភាក្សា។ ការពិភាក្សានេះ ធ្វើឡើងក្នុងគោលបំណងស្វែងយល់បន្ថែមទៀតឱ្យបានកាន់តែស៊ីជម្រៅទៅលើបញ្ហានីមួយៗ និងកំណត់បានពីឫសគល់នៃបញ្ហា និងផលប៉ះពាល់របស់វាទៅលើការដាំដុះស្វាយចន្ទីនៅកម្ពុជា។

### ២.៥ ការវិភាគទិន្នន័យ

ដោយសារតែបញ្ជីសំណួរមានប្រមាណតែ២៥០ (២៥០ Observations) នោះទិន្នន័យត្រូវបានបញ្ចូលក្នុង Excel Spreadsheet រួចវិភាគនៅក្នុងកម្មវិធី STATA។ ទិន្នន័យបែបបរិមាណ ត្រូវបានធ្វើការវិភាគ ដូចជាប្រេកង់ និងតម្លៃមធ្យម ដែលបង្ហាញក្នុងទម្រង់ជា តារាង ឬក្រាហ្វិក ជាដើម។ ដោយឡែក ទិន្នន័យតាមបែបគុណភាព នឹងត្រូវបានរៀបចំបង្ហាញក្នុងទម្រង់ជាតារាង និងរូបភាព ទៅតាមខេត្តនីមួយៗដែលបានធ្វើការសិក្សា។

## ៣. សំយោគឯកសារ

### ៣.១ ប្រវត្តិដំណាំស្វាយចន្ទី

ស្វាយចន្ទី (Anacardium occidentale) ជាប្រភេទរុក្ខជាតិតំបន់ត្រូពិច ដែលមានស្លឹកពណ៌បៃតងពេញមួយឆ្នាំ។ ស្វាយចន្ទីអាចដុះលូតលាស់កំពស់រហូត ១៤ម ខណៈដែលពូជបំបៅអាចដុះលូតលាស់បានកំពស់ប្រហែល ៦ម ដែលមានសក្តានុពលទិន្នផលខ្ពស់ និងឆាប់ទុំបើប្រៀបធៀបទៅនឹងស្វាយចន្ទីដែលដាំដោយគ្រាប់ (Morton & Dowling, 1987)។ ស្វាយចន្ទីមានដើមកំណើតនៅប្រទេសប្រេស៊ីល។ ក្នុងសម័យដែលប្រេស៊ីលស្ថិតក្រោមអាណានិគម ជនជាតិព័រទុយហ្គាល់បាននាំយកស្វាយចន្ទីទៅតំបន់ Goa នៃប្រទេសឥណ្ឌាក្នុងចន្លោះឆ្នាំ ១៥៦០ ដល់ ១៥៦៥។ ក្រោយមកទៀតស្វាយចន្ទីក៏ត្រូវបានបន្តរីកសាយនៅតំបន់អាស៊ីអាគ្នេយ៍ និងអាព្រិចផងដែរ។ នាពេលបច្ចុប្បន្ន ប្រទេសដែលមានផលិតកម្មស្វាយចន្ទីធំៗរួមមាន៖ វៀតណាម នីហ្សេរីយ៉ា ប្រេស៊ីល ឥណ្ឌា និងកូឌីវ័រ (FAO, 2014)។ គ្រាប់ស្វាយចន្ទីដែលជាទូទៅគេនិយមហៅថាចន្ទី ត្រូវបានបរិភោគពាសពេញសកលលោក។



*ក្រាភិកទី ១៖ គំនូសបំព្រួញនៃដំណាំស្វាយចន្ទី (ប្រភព: Wikiperdia, 2011)*

## ៣.២ លក្ខណៈទូទៅនៃដំណាំស្វាយចន្ទី

ស្វាយចន្ទីមានមែកសាខា មានអង្កត់ផ្ចិតលូតលាស់ប្រហែល ១០ម៉ែត្រ។ ជាការកត់សំគាល់ ដើមស្វាយចន្ទីដែលធំបំផុតនៅលើពិភពលោកស្ថិតនៅតំបន់ Natal, Rio Grande do Norte នៃប្រទេសប្រេស៊ីល ដែលដុះលូតលាស់គ្របដណ្តប់លើផ្ទៃដីប្រមាណ ៧.៥០០ ម៉ែត្រការ៉េ (Wikiperdia, 2011)។ ស្លឹករបស់វាដុះតំរៀបគ្នាជាស្ពា ផ្ទៃស្លឹករលើបដូចរោមសត្វ និងមានរាងពងក្រពើ និងស្រួចផ្នែកខាងចុងនៃស្លឹក។ ជាទូទៅស្លឹកចន្ទីមានគែមរលោង ដែលមានទទឹងចន្លោះពី ១ ទៅ ២២ ស.ម និងបណ្តោយ ៤ ទៅ ២២ ស.ម។ ផ្ការបស់វាដុះលូតលាស់នៅលើទងផ្កាដែលមានប្រវែងរហូតដល់ ២៦ ស.ម។ ផ្កាស្វាយចន្ទីជាប្រភេទផ្កាពេញលេញ មានទំហំតូច មានពណ៌បៃតងស្រាលក្នុងដំណាក់កាលដំបូង និងប្រែទៅជាពណ៌ក្រហមព្រឿងៗនៅពេលវាពេញវ័យ។

ផ្លែចន្ទីជាប្រភេទផ្លែដែលមិនមែនវិវឌ្ឍន៍មកពីអូវុលនៃផ្កាទេ តែវាវិវឌ្ឍន៍មកពីកោសិកាដែលស្ថិតនៅខាងក្រៅនៃ Carpel របស់ផ្កាទៅវិញ។ ផ្លែរបស់វាមានរាងដូចផ្លែសារីមានប្រវែងប្រហែល ៥ ទៅ ១១ ស.ម ដែលនៅពេលទុំវាប្រែទៅជាពណ៌លឿង ឬក្រហម។ ផ្លែរបស់វាអាចបរិភោគបាន មានរសជាតិផ្អែមមុត និងក្លិនផ្អែម។ សាច់ក្នុងនៃផ្លែមានទឹកច្រើនណាស់ តែសំបកផ្លែរបស់វាងាយបែកដែលពិបាកក្នុងការដឹកជញ្ជូន។



*រូបភាពទី ២៖ ដើមស្វាយចន្ទីដែលមានទំហំធំជាងគេលើពិភពលោក (Wikiperdia, 2011)*

## ៣.៣ ការប្រើប្រាស់ផលិតផលស្វាយចន្ទី

ជាទូទៅ ប៉ុន្តែមានករណីលើកលែងខ្លះ គ្រាប់ស្វាយចន្ទីត្រូវបានបរិភោគដោយអ្នកដែលមានជីវភាពបង្គួរ។ នៅពេលវាទុំ គ្រាប់ចន្ទីត្រូវបានយកមកកែច្នៃតាមរយៈការលីង ឬចំអិនដោយមានការបន្ថែមគ្រឿងផ្សំមួយចំនួនដូចជា អំបិល ឬគ្រឿងទេសដែលមានរសជាតិផ្អែមល្ហម។ គ្រាប់ស្វាយចន្ទីក៏ត្រូវបានផលិតជាប៊ឺរសម្រាប់បំពេញតម្រូវការប្រើប្រាស់ក្នុងការចំអិនម្ហូបអាហារផងដែរ។ គ្រាប់ស្វាយចន្ទីត្រូវបានគេនិយមបរិភោគជាមួយគ្រាប់រុក្ខជាតិផ្សេងៗទៀតជាអាហារសម្រន់។ ក្នុងតំបន់មួយចំនួននៃអាមេរិចខាងជើង និងអឺរ៉ុបដែលជាអ្នកប្រើប្រាស់គ្រាប់ស្វាយចន្ទីដ៏ធំនៅលើពិភពលោក គេនិយមប្រើគ្រាប់ស្វាយចន្ទីដើម្បីធ្វើនំប៉ុង សូកូឡា និងសម្រាប់ជាអាហារពេលព្រឹក (IFC, 2010)។ សំបកគ្រាប់ស្វាយចន្ទីអាចយកមកកែច្នៃធ្វើជាសម្ភារៈប្រើប្រាស់ជាច្រើនមុខទៀតដូចជា ផលិតជាប្រេងម៉ាស៊ីន ការការពារជម្រាបទឹក ថ្នាំលាប និងគ្រឿងយុទ្ធភ័ណ្ឌផ្សេងៗទៀត ក្នុងសម័យសង្គ្រាមលោកលើកទី២ (Jostock, 1996)។ ចំណែកផ្លែរបស់វាមានពណ៌ក្រហមស្រាលទៅលឿង ដែលគេនិយមប្រើវាដើម្បីចំរាញ់ចេញជាចាហួយ ឬទឹកផ្លែឈើ ឬក៏បិទដើម្បីផលិតជាស្រា។ នៅអាមេរិចឡាទីន គេយកផ្លែចន្ទីផលិតជាទឹកផ្លែឈើដែលមានរសជាតិឈ្ងុយស្រស់ស្រដៀងទៅនឹងរសជាតិចំរុះនៃទឹកផ្លែស្វាយ ម្នាស់ ប្លោកស្រស់ និងរសជាតិទំពាំងបាយជូរ (IFC, 2010)។

## ៣.៤ ទំហំផលិតកម្ម និងតម្រូវការគ្រាប់ស្វាយចន្ទីលើសកលលោក

ស្វាយចន្ទីជាដំណាំដែលងាយស្រួលដាំ អាចដុះលូតលាស់លើដីស្ទើរគ្រប់ប្រភេទ ជាពិសេសដីដែលខ្សត់ជីជាតិដែលដំណាំដទៃទៀតពិបាកដុះលូតលាស់បាន។ ស្វាយចន្ទីអាចផលិតគ្រាប់ដែលសម្បូណ៌ទៅដោយសារធាតុចិញ្ចឹមខ្ពស់ ជាមួយការចំណាយតិច។ ស្វាយចន្ទីក៏ត្រូវបានគេប្រើប្រាស់ដើម្បីទប់ស្កាត់ការហូរច្រោះដីដែរ។ ស្វាយចន្ទីត្រូវបានគេហៅថាជាដំណាំសម្រាប់អ្នកក្រ ដោយសារភាគច្រើននៃស្វាយចន្ទីត្រូវបានដាំដុះដោយកសិករក្រីក្រ ដែលមានផ្ទៃដីដាំដុះតូចសម្រាប់បង្កើនប្រាក់ចំណូលដើម្បីផ្គត់ផ្គង់តម្រូវការថ្នាំសង្កូវ ឬជាប្រភពថាមពលសម្រាប់ចំអិនម្ហូបអាហារក្នុងគ្រួសារតែប៉ុណ្ណោះ។ ជាធម្មតា ស្វាយចន្ទីចាប់ផ្តើមផ្តល់ផលនៅពេលដែលវាមានអាយុ ៤ ឬ ៥ឆ្នាំក្រោយដាំដោយគ្រាប់ និង ២ ឬ ៣ ឆ្នាំសម្រាប់ការដាំដោយកូនបំបៅ។ ស្វាយចន្ទីអាចមានរយៈពេលផ្តល់ផលពី ១៨ ទៅ ២៥ ឆ្នាំ។

ដំណាំស្វាយចន្ទី ត្រូវបានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាលក្ខណៈឧស្សាហកម្មនៅប្រទេសឥណ្ឌាក្នុងអំឡុងឆ្នាំ ១៩២០ ក្រោយពីវិធីសាស្ត្រកែច្នៃគ្រាប់ស្វាយចន្ទីដោយមានអត្រាបែកគ្រាប់ក្នុងកម្រិតទាប និងគ្មានការលាយឡំរវាងសាច់នៃគ្រាប់ស្វាយចន្ទីជាមួយនឹងសារធាតុពុលដែលមានក្នុងសំបកគ្រាប់ (IFC, 2010)។ ចាប់ពីឆ្នាំ ១៩២០ ដល់ ១៩៧០ ផ្ទៃដីដាំដុះស្វាយចន្ទីមានការកើនឡើងជាលំដាប់នៅអាព្រិចខាងត្បូង និងឥណ្ឌា។ ក្រោយមកទៀត ផ្ទៃដីដាំដុះស្វាយចន្ទីក៏បន្តរីករាលដាលយ៉ាងខ្លាំងក្នុងប្រទេសឥណ្ឌា វៀតណាម និងប្រេស៊ីលចាប់តាំងពីទសវត្សទី ៩០ មក ។ ប្រទេសឥណ្ឌាមានផ្ទៃដីដាំដុះស្វាយចន្ទីច្រើនប្រទេសដទៃទៀត គឺប្រមាណ ២៣% ខណៈដែលផលិតកម្មស្វាយចន្ទីវៀតណាម (ដោយរួមទាំងកម្ពុជា) មានប្រមាណ ១៥% ក្នុងឆ្នាំ ២០០៩ (IFC, 2010) ដែលជាប្រទេសផលិតគ្រាប់ស្វាយចន្ទី និងជាអ្នកនាំចេញស្វាយចន្ទីធំៗ រួមទាំងគ្រាប់ចន្ទីដែលមិនទាន់កែច្នៃ និងគ្រាប់ដែលបានកែច្នៃរួចរាល់។ គ្រាប់ស្វាយចន្ទី ភាគច្រើនត្រូវបាននាំចេញពីប្រទេសវៀតណាម ប្រេស៊ីល និងឥណ្ឌាទៅកាន់ទីផ្សារនានាលើពិភពលោក ខណៈដែលប្រទេសវៀតណាម និងឥណ្ឌាជាប្រភពនាំចូលគ្រាប់ស្វាយចន្ទីដែលមិនទាន់កែច្នៃពីប្រទេសនានា ដើម្បីបំពេញតម្រូវការរោងចក្រកែច្នៃរបស់ខ្លួនដើម្បីនាំចេញជាផលិតផលសម្រេច (Red River Food, Inc, 2011)។




*ក្រាភិកទី ២៖ គំនូសបំព្រួញពីដំណើរការពាណិជ្ជកម្មគ្រាប់ស្វាយចន្ទីដែលកែច្នៃ និងមិនទាន់កែច្នៃនៅលើពិភពលោកក្នុងឆ្នាំ ២០១១ (ប្រភព: Red River Food, Inc, 2011)*

បច្ចុប្បន្ននេះមានប្រទេសធំៗចំនួន ៥ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់គ្រាប់ស្វាយចន្ទីសម្រាប់ពិភពលោក។ នាប៉ុន្មានឆ្នាំចុងក្រោយនេះ វៀតណាមបានក្លាយជាប្រទេសដែលមានផលិតកម្មស្វាយចន្ទីធំជាងគេបង្អស់លើពិភពលោក។ បច្ចុប្បន្ននេះ ៣០០.០០០ ហ.ត ដែលមានទិន្នផលជាមធ្យម ១ ត/ហ.ត។ នីហ្សេរីយ៉ាជាប្រទេសមានផលិតកម្មស្វាយចន្ទីធំលំដាប់ទី ២ លើពិភពលោក។ ក្នុងឆ្នាំ ២០១៣ ទំហំនាំចេញគ្រាប់ស្វាយចន្ទីរបស់នីហ្សេរីយ៉ាមានទំហំ ១០៨ លានដុល្លាអាមេរិចស្មើនឹង ១០% នៃផលិតផលកសិកម្មនាំចេញសរុបនៃប្រទេសនេះ។ នីហ្សេរីយ៉ាមានទំហំផលិតកម្មប្រចាំឆ្នាំ ១២០.០០០ តោនក្នុងមួយឆ្នាំៗ។ ឥណ្ឌាបានធ្លាក់ចំណាត់ថ្នាក់របស់ខ្លួនមកត្រឹមលំដាប់ទី ៣។ ក្នុងឆ្នាំ ២០១៦ នេះឥណ្ឌាបាននាំចេញ ៦៥% នៃផលិតកម្មចន្ទីសកលលោក។ ទីផ្សារនាំចេញគ្រាប់ស្វាយចន្ទីរបស់ឥណ្ឌាមានជាង ៦០ ប្រទេសរួមមាន៖ ចក្រភពអង់គ្លេស អាល្លឺម៉ង់ បារាំង អេស្ប៉ាញ សហរដ្ឋអាមេរិច ជប៉ុន និងប្រទេសមួយចំនួនទៀតនៅមជ្ឈឹមបូព៌ា។ កូឌីវ័រក៏ជាប្រទេសដែលផលិតស្វាយចន្ទីដ៏ធំមួយដែរ។ ប្រទេសនេះជាប់ចំណាត់ថ្នាក់ទី ៤ ដែលទឹកប្រាក់នាំចេញគ្រាប់ស្វាយចន្ទីរបស់ប្រទេសនេះមានចំនួន ៤,៦៩ លានដុល្លាអាមេរិច ជាមួយនឹងទំហំផលិតកម្មប្រមាណ ៦២៥.០០០ តោនក្នុងឆ្នាំ ២០១៦។ នាឆ្នាំខាងមុខ ផលិតកម្មស្វាយចន្ទីរបស់នីហ្សេរីយ៉ាត្រូវបានរំពឹងថានឹងកើនដល់ ៧០០.០០០ តោន។ ប្រទេសបេនីន ឈរនៅលំដាប់ទី ៥ ក្នុងពិភពលោកជាមួយនឹងទំហំផលិតកម្ម ១២០.០០០ តោន មានផ្ទៃដីដាំដុះប្រមាណ ២០០.០០០ ហ.ត ក្នុងឆ្នាំ ២០១៦។ ជាមួយនឹងបទពិសោធន៍ជាងពីរទសវត្សរបស់ខ្លួនផ្នែកពាណិជ្ជកម្មគ្រាប់ស្វាយចន្ទី បេនីនបាននាំចេញគ្រាប់ស្វាយចន្ទីប្រមាណ ៨% ដែលស្មើនឹង ២៨% នៃផលិតកសិកម្មរបស់ខ្លួនទៅកាន់ពិភពលោក (Sijisha, 2016)។

## ៣.៥ ស្ថានភាពទូទៅនៃដំណាំស្វាយចន្ទីនៅប្រទេសកម្ពុជា

### ៣.៥.១ ផ្ទៃដីដាំដុះដំណាំស្វាយចន្ទីនៅកម្ពុជា

ដោយសារការធ្វើកំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍របស់រាជរដ្ឋាភិបាល បានជម្រុញអោយមានការរីកចំរើនលើវិស័យសាធារណៈ និងសកម្មភាពអភិវឌ្ឍន៍នានា។ គេសង្កេតឃើញថាកម្ពុជាបាននាំចេញផលិតផលកសិកម្មរបស់ខ្លួនស្ទើរតែទាំងស្រុងក្រោមរូបភាពជាវត្ថុធាតុដើម (ផលិតផលមិនទាន់កែច្នៃ) ទៅកាន់ប្រទេសជិតខាងជាពិសេសវៀតណាម។ កត្តានេះបានជម្រុញឱ្យមានការរីកចំរើនក្នុងវិស័យសេដ្ឋកិច្ច ជាពិសេសការធ្វើពាណិជ្ជកម្មរវាងកម្ពុជាជាមួយប្រទេសជិតខាងពិសេសប្រទេសវៀតណាម។ ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងវៀតណាមមានការកើនឡើងជាលំដាប់ក្នុងអត្រាប្រមាណ ១,២០០ លានដុល្លាជារៀងរាល់ឆ្នាំ (Padwe, 2011)។

ក្នុងឆ្នាំ ២០០៥ ផ្ទៃដីដាំដុះស្វាយចន្ទីរបស់កម្ពុជាមានប្រមាណ ៦០.៨៧៤ ហ.ត ដែលមានទំហំផលិតកម្មប្រមាណ ៥០.០០០ តោន ឬប្រមាណ ១,៣% នៃផលិតកម្មគ្រាប់ស្វាយចន្ទីរបស់ពិភពលោក ខណៈដែល ៩៥% នៃផលិតផលគ្រាប់ស្វាយចន្ទីត្រូវបាននាំចេញទៅកាន់ប្រទេសវៀតណាម (Chan, 2007)។ ផ្ទៃដីដាំដុះស្វាយចន្ទីនៅកម្ពុជាបានបន្តកើនឡើងជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ ២០១៣ ផ្ទៃដីដាំដុំស្វាយចន្ទីមានមានប្រមាណ ៦០ ០០០ ហ.ត ឬស្មើនឹង ១៧% នៃផ្ទៃដីដាំដុះដំណាំអាយុកាលវែងនៅកម្ពុជា។ មានខេត្តចំនួន ៧ ដែលមានផ្ទៃដីដាំដុះស្វាយចន្ទីធំជាងគេរួមមាន៖ រតនគិរី (១៨.០០០ ហ.ត) កំពង់ធំ (១៤.០០០ ហ.ត) កំពង់ចាម (១០.០០០ ហ.ត) ក្រចេះ (៨.០០០ ហ.ត) ត្បូងឃ្មុំ ស្ទឹងត្រែង និងកោះកុង (NIS, 2015)។ ស្ថានភាពផលិតកម្មស្វាយចន្ទីរបស់កម្ពុជាមានលក្ខណៈប្រហាក់ប្រហែលទៅនឹងប្រទេសផលិតគ្រាប់ស្វាយចន្ទីតូចៗដទៃទៀតដែរ គឺនៅត្រង់ថាចម្ការតូចៗមាននៅលាយឡំជាមួយចម្ការធំៗ។




*ក្រាភិកទី ៣៖ ខេត្តដែលមានផ្ទៃដីដាំដុះស្វាយចន្ទីច្រើនជាងគេទាំង ៧ នៅកម្ពុជា*

*(ប្រភព: NIS, 2015)*

### ៣.៥.២ ផលិតកម្ម និងតម្រូវការស្វាយចន្ទីក្នុងប្រទេសកម្ពុជា

ទំហំផលិតកម្មស្វាយចន្ទីរបស់កម្ពុជាមានចន្លោះពី ៣០.០០០ ទៅ ១០០.០០០ តោនក្នុងឆ្នាំ ២០១០។ ផលិតផលគ្រាប់ស្វាយចន្ទីរបស់កម្ពុជា មានតំណាងប្រមាណ ២% នៃផលិតកម្មគ្រាប់ស្វាយចន្ទីនៅលើសកលលោក ដែលជួយឱ្យកម្ពុជាបានក្លាយជាប្រទេសដែលមានផលិតកម្មស្វាយចន្ទីលំដាប់ទី ១០ ក្នុងឆ្នាំ ២០១០ (IFC, 2010)។ ស្វាយចន្ទីនៅកម្ពុជាមានទិន្នផលមធ្យមប្រមាណ ៧០០ គ.ក្រ ខណៈដែលអាកាសធាតុអំណោយផល ទិន្នផលអាចកើនឡើងដល់ ២ ត/ហ.ត គឺប្រហាក់ប្រហែលនឹងប្រទេសឥណ្ឌូនេស៊ី និងប្រទេសមួយចំនួនក្នុងទ្វីបអាព្រិច (IFC, 2010)។ យ៉ាងណាមិញ គ្រាប់ស្វាយចន្ទីរបស់កម្ពុជាមានលក្ខណៈពិសេស ដែលត្រូវបានទទួលស្គាល់ជាប្រទេសដែលនាំចេញគ្រាប់ស្វាយចន្ទី។ លក្ខណៈពិសេសៗនៃគ្រាប់ស្វាយចន្ទីរបស់កម្ពុជារួមមានៈ គ្រាប់មានគុណភាព និងទំហំធំល្អ (២៤ ទៅ ២៨% ធំជាងគ្រាប់ស្វាយចន្ទីរបស់វៀតណាម) ដែលធ្វើឱ្យមានបរិមាណបែកតិចនៅក្នុងអំឡុងពេលកែច្នៃ និងលក់បានតម្លៃខ្ពស់ជាងគ្រាប់ចន្ទីរបស់វៀតណាម (IFC, 2010)។

ទោះជាយ៉ាងណា ក៏ប្រទេសកម្ពុជាមិនទាន់មានឧស្សាកម្មកែច្នៃស្វាយចន្ទី នៅក្នុងប្រទេសរបស់ខ្លួននៅឡើយទេ ខណៈដែលមានបរិមាណផលិតកម្មធំជាងប្រទេសភីលីពីន (៥.០០០ តោន) និងស្រីលង្កា (៥.៥០០ តោន) ដែលប្រទេសទាំងពីរនេះឧស្សាហកម្មកែច្នៃគ្រាប់ស្វាយចន្ទី។ ជាការកត់សំគាល់ បរិមាណប្រមាណ ៣០.០០០ តោនក្នុងមួយឆ្នាំ អាចទ្រទ្រង់ដំណើរការឧស្សាហកម្មកែច្នៃគ្រាប់ស្វាយចន្ទី។

ផលិតកម្មស្វាយចន្ទីនៅកម្ពុជា មានសក្តានុពលយ៉ាងខ្លាំងក្នុងការលើកកំពស់ជីវភាពប្រជាជនពិសេសអ្នកដែលរស់នៅតាមជនបទ។ វិស័យនេះបានរួមចំណែកបង្កើតរាប់ពាន់ការងារសម្រាប់អ្នកក្រីក្រនៅតាមជនបទ។ ក្នុងឆ្នាំ២០១៥ កម្ពុជាបាននាំចេញស្វាយចន្ទីប្រមាណ ៨៧.៨៥៣ តោនទៅកាន់ទីផ្សារពិភពលោក (Cheng, 2017)។ យោងតាមទិន្នន័យរបស់ក្រសួងពាណិជ្ជកម្មបានបង្ហាញថា គ្រាប់ចន្ទីចន្លោះប្រហែលពី ១២៥.០០០ ទៅ ១៥០.០០០ តោន ត្រូវបាននាំចេញទៅកាន់ទីផ្សារវៀតណាមដោយគ្មានច្បាប់ត្រឹមត្រូវក្នុងឆ្នាំ ២០១៦ (Cheng, 2017)។

យ៉ាងណាក៏ដោយ យោងតាមទិន្នន័យនៃការនាំចេញបានបង្ហាញថា ទំហំនាំចេញគ្រាប់ស្វាយចន្ទីរបស់កម្ពុជាមានការធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ។ ជាក់ស្តែង អត្រានាំចេញគ្រាប់ស្វាយចន្ទីបានធ្លាក់ចុះ ១៥% ក្នុងឆ្នាំ ២០១៦ (Cheng, 2017)។ ក្នុងឆ្នាំ ២០១៦ គ្រាប់ស្វាយចន្ទីមានតម្លៃជាមធ្យម ១.៥ ដុល្លាសហរដ្ឋអាមេរិចក្នុង ១ គ.ក ហើយកម្ពុជាមានផ្ទៃដីដាំដុះស្វាយចន្ទីប្រមាណ ៦៤.៨៤០ ហ.ត ក្នុងនោះផ្ទៃដីប្រមូលផលមានប្រមាណ ៤០.៧៤៥ ហ.ត (Cheng, 2017)។

## ៤ .លទ្ធផល និងការពិភាក្សា

### ៤.១ ព័ត៌មានទូទៅរបស់អ្នកឆ្លើយតបក្នុងការសិក្សា

កសិករដាំស្វាយចន្ទីដែលបានសំភាសន៍ មាន ៥៤ ភាគរយ គឺជាបុរស និង ៤៦ ភាគរយ គឺជាស្ត្រី ដែលពួកគេ ៥៣ភាគរយជាប្តី និង ៤៣ភាគរយជាប្រពន្ធ ហើយក្រៅពីនេះគឺជាសាច់ញាតិនិងកូនដែលគ្រាប់អាយុសំភាសន៍។ ដូច្នេះ ពួកគាត់អាចជាមនុស្សសំខាន់នៅក្នុងគ្រួសារក្នុងការសម្រេចចិត្តនានា ជាពិសេសពាក់ព័ន្ធនឹងការងារដាំស្វាយចន្ទី។ ប៉ុន្តែ កម្រិតវប្បធម៌របស់ពួកគាត់នៅទាប ដោយក្នុងចំណោមពួកគាត់ គេឃើញមានតែ ២៣ភាគរយបានបញ្ចប់ថ្នាក់ទី៩ចំណេះទូទៅ ដែលស្តង់ដាកំណត់តម្រូវឱ្យពលរដ្ឋកម្ពុជាបញ្ចប់។ លើសពីនេះទៅទៀត ពួកគេ ២៣ ភាគរយ មិនចេះអក្សរទេ ហើយស្ទើរតែពាក់កណ្តាល ឬ ៤៦ភាគរយ នៃកសិករស្វាយចន្ទីដែលបានសំភាសន៍រៀនចប់បឋមសិក្សា។ គ្រួសារនីមួយៗនៃពួកគេរស់នៅមានគ្នាជាមធ្យម ៤,៨៦ នាក់ ដែលមានសមាជិកស្ត្រីជាមធ្យមមាន ២,៣២ នាក់ និងអ្នកដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅមាន ៣,១៦ នាក់។

*តារាងទី ១៖ ព័ត៌មានពីកសិករនិងគ្រួសារកសិករដាំដំណាំស្វាយចន្ទី*

| | | ចំនួន | ភាគរយ |
|---|---|---|---|
| ភេទ | ប្រុស | 135 | 54 |
| | ស្រី | 115 | 46 |
| | សរុប | 250 | 100 |
| ទំនាក់ទំនងក្នុងគ្រួសារ | ប្តី | 132 | 53 |
| | ប្រពន្ធ | 107 | 43 |
| | កូន | 7 | 3 |
| | សាច់ញាតិ | 4 | 2 |
| | សរុប | 250 | 100 |
| កម្រិតវប្បធម៌ | មិនចេះអក្សរ | 57 | 23 |
| | បឋមសិក្សា | 114 | 46 |
| | មធ្យមសិក្សា | 59 | 24 |
| | វិទ្យាល័យ | 19 | 7,5 |
| | សកលវិទ្យាល័យ | 1 | 0,5 |
| | សរុប | 250 | 100 |

| | | គិតជាមធ្យម | ចំនួនសមាជិកគ្រួសារខុសគ្នាពីមួយទៅមួយ |
|---|---|---|---|
| ទំហំគ្រួសារ | សមាជិកគ្រួសារ | 4.86 | 1.736 |
| | សមាជិកគ្រួសារជាស្ត្រី | 2.32 | 1.103 |
| | សមាជិកគ្រួសារអាយុចាប់ពី ១៨ឆ្នាំ | 3.16 | 1.497 |

កសិករដែលបានសំភាសន៍ទាំងនោះ ភាគច្រើនរស់នៅក្នុងមូលដ្ឋាននោះតាំងពីកំណើត។ អ្នកដែលមកតាំងទីលំនៅថ្មីមាន ១២ភាគរយ ដែលក្នុងនោះ ៥ភាគរយមកពីខេត្តផ្សេងៗ។ មូលហេតុដែលពួកគេមកតាំងទីលំនៅក្នុងមូលដ្ឋានដែលបានសំភាសន៍ គឺដោយសារការទាក់ទាញពីការធ្វើកសិកម្មបានផលច្រើន ឬក៏ការទាក់ទាញឱ្យមករស់នៅដោយសាច់ញាតិ។ ពួកគេមានមុខរបរសំខាន់បី គឺ ៩៨ភាគរយជាធ្វើចម្ការ ហើយ ៤១ ភាគរយ នៃពួកគេអាចធ្វើស្រែ និង ១៤ភាគរយទៀតអាចលក់ដូរកំប៉ិចកំប៉ុកបន្ថែម។

*តារាងទី ២៖ ការតាំងទីលំនៅថ្មីនៃគ្រួសារកសិករដាំដំណាំស្វាយចន្ទី*

| | | ចំនួន | ភាគរយ |
|---|---|---|---|
| ការតាំងទីលំនៅថ្មី | តាំងពីកំណើត | 219 | 88 |
| | អ្នកចំណូលថ្មី | 30 | 12 |
| | សរុប | 250 | 100 |
| បើអ្នកចំណូលថ្មី | មកពីខេត្តដែលកំពុងរស់នៅ | 17 | 7 |
| | មកពីខេត្តផ្សេង | 13 | 5 |
| | សរុប | 30 | 12 |
| មូលហេតុនៃការតាំងទីលំនៅថ្មី | ធ្វើកសិកម្ម | 15 | 6 |
| | តាមសាច់ញាតិ | 15 | 6 |
| | សរុប | 30 | 12 |
| មុខរបរសំខាន់ | ធ្វើចម្ការ | 246 | 98 |
| | ធ្វើស្រែ | 2 | 1 |
| | លក់កម្លាំងពលកម្ម | 1 | 0.5 |
| | មន្ត្រីរាជការ | 1 | 0.5 |
| | សរុប | 250 | 100 |

| | | | |
|---|---|---|---|
| មុខរបរទីពីរ | ធ្វើចម្ការ | 2 | 1 |
| | ធ្វើស្រែ | 102 | 41 |
| | អ្នកលក់ដូរ | 34 | 14 |
| | លក់កម្លាំងពលកម្ម | 7 | 3 |
| | មន្ត្រីរាជការ | 2 | 1 |
| | សរុប | 147 | 59 |

## ៤.២ ការដាំដុះ និងប្រមូលផល

### ៤.២.១ ប្រតិទិនដំណាំស្វាយចន្ទី

ការសិក្សានេះ មានដែនកំណត់ត្រឹមតែកសិករដែលមានចម្ការស្វាយចន្ទីប្រមូលផលបានប៉ុណ្ណោះ ប៉ុន្តែក្រុមពិភាក្សាបានផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយពីខ្សែសង្វាក់ផលិតកម្មដំណាំស្វាយចន្ទីរបស់កសិករទូទៅ។ កសិករបានឱ្យដឹងថា ភាគច្រើននៃចម្ការស្វាយចន្ទីបានដាំពីកូនស្វាយចន្ទី មិនមែនដាំពីគ្រាប់នោះទេ។ បច្ចុប្បន្ននេះ កូនស្វាយចន្ទីដែលយកមកដាំនេះគឺជាកូនដែលបានតត្រួយ ដែលមានគល់ជាពូជកូនស្វាយចន្ទីខ្មែរ និងចុងជាកូនស្វាយចន្ទីពូជអឺម ឬពូជផ្សេងទៀតដូចជា ម៉ាឡេស៊ីនិងពូជថៃជាដើម។

កសិករដែលបានសំភាសន៍បានឱ្យដឹងថា ពួកគាត់មួយចំនួនតូចហាក់ដូចជាបានអនុវត្តន៍ប្រតិទិននៃការថែទាំបំប៉នស្វាយចន្ទី ដើម្បីឱ្យបានផ្លែផ្កាល្អនិងប្រមូលផលស្វាយចន្ទី ងាកចេញពីរដូវកាលដើម ដោយហេតុពីកត្តាពូជ និងកត្តាអាកាសធាតុដែលមានឥទ្ធិពលលើស្ថានភាពចម្ការ។ ទោះជាការដាំកូនដូចជាជៀសតែរដូវក្តៅខ្លាំង ប៉ុន្តែកសិករជាច្រើននាក់នៅចាប់ផ្តើមការថែទាំគឺ ពីខែឧសភា ដល់ខែកក្កដា ហើយការប្រមូលផលនៅតែចាប់ផ្តើមពីខែកុម្ភៈដល់ខែមេសា។ ភាគច្រើននៃកសិករប្រមូលផលស្វាយចន្ទីនៅខែមីនា។ ដូច្នេះ អាចសំគាល់បានថា សកម្មភាពឈ្មួញនឹងមានសភាពមមាញឹកនៅកំឡុងខែនៃរដូវក្តៅទាំងនោះ ដែលអំណោយផលដល់ការដឹកជញ្ជូនស្វាយចន្ទីពីចម្ការមកផ្ទះ ឬទីតាំងលក់។

*តារាងទី ៣៖ ប្រតិទិនពីការដាំ និងការប្រមូលផលនៃដំណាំស្វាយចន្ទី*

| ល.រ | សកម្មភាព | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ការជ្រើសរើសពូជបណ្តុះកូន និងតត្រួយ | | | | | | | | | | | | |
| ២ | ការរៀបចំដីដាំ | | | | | | | | | | | | |
| ៣ | ការដាំពីកូនតត្រួយ | | | | | | | | | | | | |
| ៤ | ការកាត់ស្មៅ | | | | | | | | | | | | |
| ៥ | ការបាញ់ថ្នាំ | | | | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៦ | ដាក់ជីបំប៉នដើម | | | | | | | | | | | | |
| ៧ | ស្វាយចន្ទីចេញផ្កា | | | | | | | | | | | | |
| ៧ | ការប្រមូលផល | | | | | | | | | | | | |

### ៤.២.២ ពូជស្វាយចន្ទី

ភាគច្រើននៃកសិករដាំស្វាយចន្ទីប្រើប្រាស់ពូជអឹម០៩ ពូជអឹម២១ ពូជអឹម២៣ ពូជស្វាយចន្ទីប្រពៃណីខ្មែរ និងពូជផ្សេងៗទៀត។ កសិករដែលដាំស្វាយចន្ទីដំបូងៗគេ បានប្រើពូជស្វាយចន្ទីប្រពៃណីខ្មែរ។ តាមរយៈការកសិកម្មទំនើប ពូជថ្មីៗរបស់ស្វាយចន្ទីត្រូវបាននាំចូល ឬបង្កាត់ និងផ្សព្វផ្សាយ ហើយពួកវានឹងមានផលិតភាព និងតម្លៃទីផ្សារខ្ពស់ រួមទាំងអំណោយផលផ្សេងៗ។ និន្នាការប្តូរពីចម្ការពូជស្វាយចន្ទីប្រពៃណីខ្មែរ ទៅដាំពូជអឹម២៣ កាន់តែកើនឡើង ដោយឥឡូវនេះចម្ការដែលដាំពូជស្វាយចន្ទីប្រពៃណីខ្មែរទាំងនោះអាចមានអាយុជិត២០ឆ្នាំហើយ ដែលមានដើមស្វាយចន្ទីធំៗ និងខ្ពស់ៗ។ មានផលិតភាពតិច និងពិបាកថែទាំ។ លក្ខណៈពិសេសនៃគ្រាប់របស់ផ្លែស្វាយចន្ទីនៃពូជស្វាយចន្ទីប្រពៃណីខ្មែរមានសំបកក្រាស់ និងសាច់គ្រាប់តូច ឯពូជប្រភេទអឹម២៣ មានសំបកស្តើង និងសាច់គ្រាប់ធំ។ ដូច្នេះ ពូជប្រភេទអឹម២៣ មានសក្តានុពលទាក់ទាញឱ្យទទួលយកពីកសិករ ដោយពុំទាន់គិតគូរពីបច្ចេកទេសដាំ និងការថែទាំនៅឡើយ។

ទោះបីជាកសិករប្តូរមកដាំ ពូជប្រភេទ អឹម២៣ ក៏ដោយ ក៏ពួកគាត់មិនអាចបោះបង់ចោលពូជស្វាយចន្ទីខ្មែរឡើយ ដោយសារកសិករបណ្តុះកូនពូជស្វាយចន្ទីខ្មែររួចកាត់តត្រួយពីកូន ឬ ដើមនៃពូជប្រភេទ អឹម២៣ ។ បច្ចេកទេសតត្រួយដោយឫសនិងគល់របស់ពូជស្វាយចន្ទីខ្មែរ អាចជានាឱ្យមានការលូតលាស់ល្អ ធន់នឹងជំងឺ ប្រភេទដី និងធាតុអាកាសក្នុងតំបន់។ ដូច្នេះ កសិករនឹងជួបការលំបាកខ្វះកម្លាំងពលកម្ម ឬ ថវិកាទិញពូជថ្មី ប្រសិនបើនិន្នាការនៃការប្តូរពូជ និងបច្ចេកទេសតត្រួយរបៀបនេះនឹងបន្តកើនឡើង ។

*តារាងទី ៤៖ ពូជស្វាយចន្ទីដែលដាំដោយកសិករក្នុងតំបន់សិក្សា*

| ល.រ | ពូជស្វាយចន្ទី | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | ពូជស្វាយចន្ទីខ្មែរ | 112 | 45 |
| ២ | ពូជ អឹម០៩ | 2 | 1 |
| ៣ | ពូជ អឹម២១ | 2 | 1 |
| ៤ | ពូជ អឹម២៣ | 127 | 51 |
| ៥ | ផ្សេងៗ | 7 | 3 |
| | សរុបគ្រួសារសំភាសន៍ | 250 | 100 |

កសិករដែលនៅបន្តដាំពូជស្វាយចន្ទីខ្មែរមានប្រហែល ៤៤ភាគរយ និង កសិករដែលដាំពូជប្រភេទ អឹម២៣ មាន ៥២ភាគរយ។ ការពិតមូលហេតុដែលកសិករនៅបន្តដាំពូជស្វាយចន្ទីខ្មែរ គឺដោយពួកគាត់ប្រហែលជា ៣២ ភាគរយ អះអាងថា មិនមានពូជទំនើបដែលគាត់ទទួលយកបាន។ ចំណែកឯកសិករ ២០ភាគរយ ដែលដាំពូជអឹម២៣ លើកឡើងដោយពេញចិត្តថា គាត់ទទួលបានសាច់គ្រាប់ធំ និង ១៩ ភាគរយ លើកឡើងថា គាត់ទទួលបានទិន្នផលខ្ពស់។

*តារាងទី ៥៖ មូលហេតុនៃការជ្រើសរើសពូជស្វាយចន្ទីដែលដាំ (ចំនួនគ្រួសារ ២៥០នាក់)*

| លរ | មូលហេតុ | ពូជស្វាយចន្ទីខ្មែរ | ពូជ M23 | ពូជស្វាយចន្ទីខ្មែរ | ពូជ M23 |
|---|---|---|---|---|---|
| | | ចំនួន | | ភាគរយ | |
| ១ | គ្រាប់ធំសាច់ធំ | 6 | 51 | 2.4 | 20.4 |
| ២ | ទិន្នផលខ្ពស់ | 4 | 47 | 1.6 | 18.8 |
| ៣ | ពេញនិយមដាំ | 15 | 22 | 6.0 | 8.8 |
| ៤ | លក់បានថ្លៃខ្ពស់ | 1 | 1 | 0.4 | 0.4 |
| ៥ | គ្រាប់វែង | 1 | 0 | 0.4 | |
| ៦ | គ្រាប់ធូន់ | 0 | 1 | | 0.4 |
| ៧ | ធន់នឹងជំងឺ | 2 | 1 | 0.8 | 0.4 |
| ៨ | ឆាប់ទទួលផល | 1 | 2 | 0.4 | 0.8 |
| ៩ | លក់បានថ្លៃទាប | 2 | 3 | 0.8 | 1.2 |
| ១០ | គ្មានពូជទំនើបផ្សេងទៀត | 79 | 2 | 31.6 | 0.8 |
| | សរុប | 111 | 130 | 44.4 | 52.0 |

ចំណេះដឹងកសិករលើការយល់ដឹងពីប្រភពនៃពូជស្វាយចន្ទីនៅក្នុងការសិក្សាពេលនេះ គឺមិនបានកំណត់ ត្រឹមតែពូជដែលគាត់ដាំជាកូន ឬជាគ្រាប់នោះទេ ។ ភាគច្រើននៃកសិករដែលបានសំភាសន៍ប្រមាណ ៦៨ ភាគរយ បានទិញកូនឬគ្រាប់ពី អ្នកបណ្តុះកូនក្នុងភូមិគាត់ ឬភូមិឃុំក្បែរខាង ហើយកសិករប្រហែល ៣០ភាគរយទៀតបានទិញកូនឬគ្រាប់ពី កសិករនៅផ្ទះក្បែរគ្នាក្នុងភូមិគាត់ ។

*តារាងទី ៦៖ ប្រភពពូជស្វាយចន្ទីដែលដាំដោយកសិករក្នុងតំបន់សិក្សា*

| លរ | ប្រភពពូជ | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | អ្នកបណ្តុះកូនក្នុងភូមិ | 171 | 68 |
| ២ | ក្រុមហ៊ុនកសិកម្ម | 3 | 1.2 |
| ៣ | ពូជថៃ | 2 | 0.8 |
| ៤ | កសិករនៅផ្ទះក្បែរគ្នា | 74 | 30 |
| | សរុបគ្រួសារសំភាសន៍ | 250 | 100 |

## ៤.៣ និន្នាការនៃការដាំដំណាំស្វាយចន្ទី

កសិករដែលបានសំភាសន៍ ក៏ត្រូវស្នើឱ្យបញ្ចេញយោបល់ពីការតាំងចិត្តដាំដំណាំស្វាយចន្ទីទៅអនាគតដែរ។ កសិករភាគច្រើនរហូតដល់ ៨៤ភាគរយ បានប្តេជ្ញាបន្តដាំដំណាំស្វាយចន្ទីរហូត ហើយ ៤ ភាគរយផ្សេងទៀតតាំងចិត្តថានឹងមិនដាំដំណាំស្វាយចន្ទីទៀតទេ ។ លើសពីនេះទៅទៀត កសិករប្រហែល ១០ ភាគរយ បានតាំងចិត្តនឹងឈប់ដាំដំណាំស្វាយចន្ទី ក្នុងរយៈពេលពី ១ - ៥ ឆ្នាំទៀត ហើយ ២ ភាគរយទៀតថា អាចនឹងឈប់ដាំដំណាំស្វាយចន្ទីពី ៥ - ១០ ឆ្នាំ។ មូលហេតុគឺ ការជួបប្រទះនឹងបញ្ហាប្រឈមគ្រោះធម្មជាតិ និងការកាន់តែបន្តកើនឡើងនៃការរាតត្បាតរបស់សត្វល្អិតបំផ្លាញ ការប្រែប្រួលតម្លៃលក់ពេលប្រមូលផល ការខ្វះខាតកម្លាំងពលកម្ម និងឥណទាន សម្រាប់ផលិតកម្ម។

*តារាងទី ៧៖ ការតាំងចិត្តដាំដំណាំស្វាយចន្ទីទៅអនាគត*

| លរ | ការតាំងចិត្ត | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | បន្តដាំរហូត | 210 | 84 |
| ២ | មិនដាំទេនៅឆ្នាំក្រោយ | 11 | 4 |
| ៣ | មិនដាំក្នុងរយៈពេល ១ - ៥ ឆ្នាំទៀត | 24 | 10 |
| ៤ | មិនដាំក្នុងរយៈពេលពី ៦-១០ ឆ្នាំទៀត | 5 | 2 |
| | សរុបគ្រួសារសំភាសន៍ | 250 | 100 |

កសិករក៏បានផ្តល់យោបល់ពីការយល់ឃើញរបស់គាត់ ចំពោះទិន្នផលដំណាំស្វាយចន្ទីកន្លងមកដែរ។ លទ្ធផលស្ទាបស្ទង់យោបល់បានឱ្យដឹងថា កសិករបានយល់ឃើញប្រទាញប្រទុងគ្នាអំពីនិន្នការទិន្នផល គឺ ៣៩ភាគរយ យល់ថា ទិន្នផលកើនឡើង ៣១ភាគរយយល់ថា ទិន្នផលនៅដដែល និង៣០ ភាគរយ យល់ថា ទិន្នផលធ្លាក់ចុះ។




*ក្រាហ្វិកទី ៤៖ ការផ្តល់យោបល់ពីនិន្នាការទិន្នផលស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់)*

ភាគច្រើននៃកសិករក្នុងចំណោម ៣៩ ភាគរយដែលយល់ថា ទិន្នផលស្វាយចន្ទីកើនឡើងមធ្យម។ ដូចគ្នានេះដែរ ភាគច្រើននៃកសិករក្នុងចំណោម ៣០ ភាគរយដែលយល់ថា ទិន្នផលស្វាយចន្ទីថយចុះមធ្យម។ យោបល់ទាំងនេះ ពិតជាឆ្លុះបញ្ចាំងពីភាពជោគជ័យនិងបរាជ័យក្នុងរបរដាំស្វាយចន្ទីរបស់កសិករម្នាក់ពោលគឺ វាបង្ហាញពីចំណេះដឹង និងបទពិសោធន៍របស់កសិករ រួមនឹងកត្តាដីចម្ការដែលផ្ដល់ផលិតភាព ហើយនឹងការដាំស្វាយចន្ទីបានផលដើមរដូវ ឬចុងរដូវ។ យោបល់ប្រទាញប្រទុងគ្នានេះជម្រុញលើកទឹកចិត្ត ឱ្យកសិកររៀនសូត្រពីគ្នាទៅវិញទៅមក ។

*តារាងទី ៨៖ ការផ្ដល់យោបល់ពីនិន្នាការទិន្នផលស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់)*

| លរ | ដំណាំ | កើនឡើង | | | ដដែល | ធ្លាក់ចុះ | | |
|---|---|---|---|---|---|---|---|---|
| | | ខ្លាំង | មធ្យម | ខ្សោយ | | ខ្លាំង | មធ្យម | ខ្សោយ |
| ១ | ទិន្នផលស្វាយចន្ទី | 10 | 67 | 21 | 78 | 20 | 37 | 17 |
| | | 4% | 27% | 8% | 31% | 8% | 15% | 7% |

## ៤.៤ ទីផ្សារ គ្រាប់ស្វាយចន្ទី

### ៤.៤.១ គុណភាពគ្រាប់ស្វាយចន្ទី

គ្រាប់ស្វាយចន្ទី គឺជាកសិផលសម្រាប់ខ្សែចង្វាក់ទីផ្សារ។ ការប្រមូលផលគ្រាប់ស្វាយចន្ទី គឺជាការរើសផ្លែស្វាយចន្ទីដែលទុំជ្រុះមកដី ហើយបេះយកតែគ្រាប់ ចំណែកឯផ្លែស្វាយចន្ទីត្រូវបានគេជាជីកំប៉ុស្ត។ គុណភាពនៃគ្រាប់ស្វាយចន្ទី គឺទាក់ទងទៅនឹងសត្វល្អិតបំផ្លាញសំបកគ្រាប់ ការប្រលាក់ដី និងការបេះគ្រាប់ចេញពីផ្លែ។ ផ្លែស្វាយចន្ទីមានទឹកជមផ្អែមក្រអូបតែរមាស់ ហើយទឹកជមនោះមានជ័រពណ៌ខ្មៅ ដែលប្រលាក់លាងមិនងាយជ្រះ។ ដូច្នេះ គុណភាពគ្រាប់ស្វាយចន្ទីដែលល្អ គឺមិនខូចដោយសត្វល្អិតបំផ្លាញ មិនប្រលាក់ដី និងមិនប្រលាក់ជ័រចេញពីគ្រាប់វា។

| រូបថត គ្រាប់មានគុណភាពល្អ | រូបថត គ្រាប់មានគុណភាពមិនល្អ |
|---|---|



*រូបភាពទី ៣៖ គុណភាពនៃគ្រាប់ស្វាយចន្ទី*

គ្រាប់ស្វាយចន្ទីអាចលក់ស្រស់ ហៅថា គ្រាប់ស្វាយចន្ទីស្រស់ គឺជាគ្រាប់ដែលទើបបេះចេញពីផ្លែ និងអាចលក់ស្ងួត ហៅថា គ្រាប់ស្វាយចន្ទីស្ងួត គឺជាគ្រាប់ដែលគេបានហាលថ្ងៃឱ្យស្ងួតទឹក។ តម្រូវការទីផ្សារគ្រាប់ស្វាយចន្ទីសព្វថ្ងៃ គឺគ្រាប់ស្វាយចន្ទីស្រស់។ តម្រូវការទីផ្សារគ្រាប់ស្វាយចន្ទីស្ងួតមិនមានទេ ប៉ុន្តែការលក់គ្រាប់ស្វាយចន្ទីស្ងួតមានតិចតួចដែរ ដោយសារកសិករមិនអាចលក់គ្រាប់ស្រស់នៅពេលដែលគ្រាប់ស្រស់មិនមានគុណភាពល្អតាមការកំណត់ពីឈ្មួញ ជាពិសេស គឺ គ្រាប់ស្វាយចន្ទីស្រស់ដែលមានសំបកខូចដោយសត្វល្អិតបំផ្លាញ។

## ៤.៤.២ តម្លៃគ្រាប់ស្វាយចន្ទី

កសិករដែលបានសំភាសន៍ទាំងអស់ សុទ្ធតែបានលក់គ្រាប់ស្វាយចន្ទីស្រស់តាំងពីដើមរដូវរហូតដល់ចុងរដូវ នៃឆ្នាំ ២០១៦ - ២០១៧។ តម្លៃដើមរដូវគឺជាតម្លៃអតិបរិមា ដែលកសិករអាចលក់គ្រាប់ស្វាយចន្ទីស្រស់បាន ៨.៥០០រៀលក្នុង១គក និងតម្លៃចុងរដូវគឺជាតម្លៃទាបបំផុត ដែលកសិករអាចលក់គ្រាប់ស្វាយចន្ទីស្រស់បាន ២.០០០រៀលក្នុង១គក។ ជួនកាលតម្លៃចុងរដូវធ្លាក់ទាបរហូតដល់ប្រហែល ១.០០០ រៀលផងដែរ។ តម្លៃប្រែប្រួលនេះគឺជាប់ទាក់ទងនឹងតម្រូវខ្ពស់ និងគុណភាពគ្រាប់ស្វាយចន្ទីដែលប្រមូលផលដើមរដូវ។ ជាទូទៅ កសិករទទួលបានតម្លៃជាមធ្យមដែលអាចលក់បាន នៅរដូវសម្បូណ៌គ្រាប់ស្វាយចន្ទីស្រស់ គឺ ៦.០០០រៀលក្នុង១គក។ ដោយទិន្នផលដើមរដូវ និងចុងរដូវប្រមូលបានតិច ហើយកសិករប្រមូលទិន្នផលគ្រាប់បានស្ទើរតែ ៧០ភាគរយ នៅកណ្តាលរដូវដូច្នេះ តម្លៃគ្រាប់ស្វាយចន្ទីស្រស់ ៦.០០០រៀលក្នុង១គក គឺជាតម្លៃដែលកសិកររំពឹងទុកជារៀងរាល់ឆ្នាំ។ នៅចុងរដូវ គុណភាពគ្រាប់ស្វាយចន្ទីប្រមូលបានអាចក្រោមកម្រិតកំណត់ ដូចជា សំបកបែកដោយសារត្រូវភ្លៀង សម្រាប់មានស្នាមដំបៅដោយសត្វល្អិតទិច សំបកប្រឡាក់ជ័រខ្មៅ និងគ្រាប់ស្តៀតជាដើម។ ដូច្នេះតម្លៃលក់គ្រាប់ស្រស់ធ្លាក់ចុះ រហូតក្រោម ១.០០០រៀល ដែលកសិករមិនអាចលក់បាន ហើយជាញឹកញយ ឈ្មួញក៏មិនទទួលទិញនោះដែរ។ ដូច្នេះអ្វីដែលជាដំណោះស្រាយ គឺ ការហាលសម្ងួតគ្រាប់ស្វាយចន្ទីស្រស់ដែលខូចគុណភាពហើយមានតម្លៃក្រោម ១.០០០ រៀលនោះ ឱ្យទៅជាគ្រាប់ស្ងួត។ គុណភាពគ្រាប់ស្ងួត គឺ គ្រាប់ជៀសវៀងតែគ្រាប់ស្តៀតគ្មានសាច់ ហើយតម្លៃគ្រាប់ស្វាយចន្ទីស្ងួតនៅឆ្នាំ ២០១៦-២០១៧ គឺ ៤,៥០០រៀល ក្នុង១គក តាមការឱ្យដឹងពីក្រុមពិភាក្សារបស់កសិករនិងឈ្មួញ។ ការប្រែប្រួលតម្លៃតាមរដូវកាល និងគុណភាព ទំហំប្រហែល ១,៣០០រៀល/គក អាចជាទំនាក់ទំនងពាណិជ្ជកម្មល្អរវាងកសិករនិងឈ្មួញ ហើយវាថែមទាំងជាកត្តាជម្រុញឱ្យមានការស្វែងរកបច្ចេកទេស និងពូជថ្មី ដែលផ្តល់ផលដើមរដូវទាន់តម្លៃលក់ខ្ពស់ទៀតផង។

*តារាងទី ៩៖តម្លៃគ្រាប់ស្វាយចន្ទីស្រស់តាមចម្ការ ឆ្នាំ ២០១៦ - ២០១៧ (ចំនួនគ្រួសារ ២៥០នាក់)*

| លរ | ចម្ការ | ចំនួនគ្រួសារ | តម្លៃអប្បរិមា | តម្លៃអតិបរិមា | តម្លៃមធ្យម | តម្លៃប្រែប្រួលដើម-ចុងរដូវ |
|---|---|---|---|---|---|---|
| ១ | តម្លៃលក់គ្រាប់ស្វាយចន្ទីស្រស់ពីចម្ការទី ១ (រៀល/គក) | 100% | ២.000 | 8.500 | 5.947 | 1.308 |
| ២ | តម្លៃលក់គ្រាប់ស្វាយចន្ទីស្រស់ពីចម្ការទី ២ (រៀល/គក) | 20% | 3.000 | 8.000 | 6.032 | 1.247 |
| ៣ | តម្លៃលក់គ្រាប់ស្វាយចន្ទីស្រស់ពីចម្ការទី៣ (រៀល/គក) | 4% | 3.500 | 8.000 | 5.944 | 1.446 |

និន្នាការនៃការប្រែប្រួលតម្លៃគ្រាប់ស្វាយចន្ទីស្រស់ក្នុងរយៈពេល បីឆ្នាំជាប់គ្នា ពី ២០១៤ ដល់ ២០១៦ បង្ហាញនូវគំលាតធំគួរឱ្យកត់សំគាល់។ ខណៈដែលតម្លៃដើមរដូវបន្តកើនឡើង ៥០០រៀល ជារៀងរាល់ឆ្នាំ តម្លៃរវាងចុងរដូវឆ្នាំ ២០១៤ និងចុងរដូវឆ្នាំ ២០១៥ នៅថេរ និងតម្លៃរវាងចុងរដូវឆ្នាំ ២០១៥ និងចុងរដូវឆ្នាំ ២០១៦កើនឡើង ៥០០រៀល។ ជាពិសេស តម្លៃមធ្យមនៅពាក់កណ្តាលរដូវបន្តកើនឡើង ១.០០០រៀល ជារៀងរាល់ឆ្នាំ ពី ៣.៥០០ រៀលឆ្នាំ ២០១៤ ទៅ ៤.៥០០ រៀល ឆ្នាំ ២០១៥ និង ៥.៥០០ រៀលឆ្នាំ២០១៦។

*តារាងទី ១០៖ តម្លៃគ្រាប់ស្វាយចន្ទីស្រស់លក់ទូទៅឆ្នាំ ២០១៤ - ២០១៦ (ចំនួនគ្រួសារ ២៥០នាក់)*

| លរ | តម្លៃ | ចំនួនគ្រួសារ | តម្លៃអប្បបរិមា | តម្លៃអតិបរិមា | តម្លៃមធ្យម | តម្លៃប្រែប្រួលដើម-ចុងរដូវ |
|---|---|---|---|---|---|---|
| ១ | តម្លៃលក់គ្រាប់ស្វាយចន្ទីស្រស់ ឆ្នាំ ២០១៤ (រៀល/គក) | 61% | 1.500 | 7.000 | 3.551 | 943 |
| ២ | តម្លៃលក់គ្រាប់ស្វាយចន្ទីស្រស់ ឆ្នាំ ២០១៥ (រៀល/គក) | 75% | 1.500 | 8.000 | 4.436 | 1.047 |
| ៣ | តម្លៃលក់គ្រាប់ស្វាយចន្ទីស្រស់ ឆ្នាំ ២០១៦ (រៀល/គក) | 87% | 2.000 | 8.500 | 5.512 | 1.314 |

លើសពីនេះទៅទៀត តម្លៃគ្រាប់ស្វាយចន្ទីស្រស់ប្រែប្រួលយ៉ាងហោចណាស់ ២ដងក្នុងមួយថ្ងៃផងដែរ ដោយសារមូលហេតុមិនច្បាស់លាស់ដែលអាចដឹងមុនបាន។ ភាគច្រើនមូលហេតុនេះសន្និដ្ឋានតាមទ្រឹស្តីសេដ្ឋកិច្ចពីការផ្គត់ផ្គង់និងតម្រូវការ គឺថា បើសិនជាមានការប្រកួតប្រជែងក្នុងការប្រមូលទិញពីសំណាក់ក្រុមខុសគ្នានៃឈ្មួញប្រមូលទិញពីកសិករនិងឈ្មួញនាំចេញ តម្លៃអាចនឹងកើនឡើង។ ប៉ុន្តែបើសិនជាកសិករប្រមូលផលបានច្រើនព្រមៗគ្នា វាអាចនាំឱ្យតម្លៃធ្លាក់ចុះ។ ទំហំថ្លៃដែលប្រែប្រួលគឺឡើងឬចុះចាប់ពី ៥០ - ១០០រៀលក្នុង១គក។ ជាទូទៅ តម្លៃទិញគ្រាប់ស្វាយចន្ទីស្រស់ កំណត់តាមទូរស័ព្ទនៅម៉ោង ៩ - ១០ ព្រឹក ហើយម៉ោង ៣រសៀល តម្លៃនោះអាចធ្លាក់ចុះចាប់ពី ៥០ - ១០០រៀលក្នុង១គក ឬនៅថេរដដែល។ ពេលបានតម្លៃពីឈ្មួញធំប្រចាំតំបន់នៅម៉ោង ៩-១០ព្រឹកហើយរួច ឈ្មួញតូចៗប្រចាំភូមិចាប់ផ្ដើមដើរប្រមូលទិញពីកសិករតាមចម្ការ ឬរង់ចាំនៅដេប៉ូរបស់ខ្លួន។ ពេលទិញរួចដល់ម៉ោង ៥ - ៦ ល្ងាច ទើបឈ្មួញតូចៗលក់បន្តឱ្យឈ្មួញធំតាមតម្លៃនៅម៉ោងនោះ។ ការប្រែប្រួលនេះបានបង្កឱ្យបង់ខាតដល់ឈ្មួញតូចៗដែលប្រមូលទិញផ្ទាល់តាមភូមិ ដោយហេតុថា តម្លៃថ្មីជាទូទៅទាបជាងតម្លៃកំណត់ក្នុងកំឡុងពេលបួនដប់ម៉ោងមុន ហើយត្រូវបានយកមកទូទាត់ជាមួយបរិមាណដែលឈ្មួញតូចៗបានទិញរួចហើយដែលធ្វើឱ្យមានការបង់ខាត។ ក្នុងថ្ងៃដដែល កសិករដែលមិនទាន់លក់ក៏ទទួលបានតម្លៃទាបទៅតាមតម្លៃថ្មីដែរ។ ឧទាហរណ៍ បើឈ្មួញក្នុងភូមិទិញបានគ្រាប់ស្វាយចន្ទីស្រស់ ៥តោន រួចហើយ ឬកសិករទើបប្រមូលគ្រាប់ស្វាយចន្ទីស្រស់បាន ៥តោននោះ ពួកគាត់អាចខាតពី ២៥០.០០០ ទៅ ៥០០.០០០ រៀល ដោយសារការធ្លាក់តម្លៃក្នុងបួនដប់ម៉ោងនោះ។ កត្តាលើកទឹកចិត្តដល់ឈ្មួញតូចៗឱ្យបន្តប្រមូលទិញ គឺ ប្រាក់ចំណេញចាប់ពី ១០០ ទៅ ២០០រៀលក្នុង១គក ពេលលក់ទៅឱ្យឈ្មួញនាំចេញ។ ថ្ងៃខ្លះប្រាក់ចំណេញនេះអាចជួយឱ្យរួចដើម ដោយសារទូទាត់ការបង់ខាតដោយការប្រែប្រួលតម្លៃប្រចាំថ្ងៃ ថ្ងៃខ្លះទៀតប្រាក់ចំណេញនេះអាចសល់តែពាក់កណ្ដាលព្រោះការទូទាត់ការបាត់បង់ទម្ងន់។ ការប្រែប្រួលនេះពុំទាន់អាចស្វែងយល់បាននៅឡើយទេទាំងកសិករ ឈ្មួញគ្រប់បណ្ដាញ។ ពួកគេគ្រាន់តែដឹងថា ឈ្មួញខាងទទួលទិញដុំប្រាប់ឱ្យទិញចុះថ្លៃតាមកំណត់នោះ។ ដូច្នេះវាបង្ហាញពីចារិកទីផ្សារសេរីប្រែប្រួលប្រចាំថ្ងៃអនុវត្តន៍ដោយមិនមានកិច្ចសន្យាប្រចាំថ្ងៃ ហើយវាក៏មិនមានការសម្របសម្រួលពីអាជ្ញាធរជំនាញ ណាមួយឡើយ។

## ៤.៩ ខ្សែសង្វាក់ផលិតកម្មស្វាយចន្ទី

### ៤.៩.១ អ្នកផ្គត់ផ្គង់ធាតុចូល

ដំណាំស្វាយចន្ទី ត្រូវការរយៈពេល ៣ឆ្នាំ ដើម្បីលូតលាស់មុននឹងផ្ដល់ផ្លែផ្កាជាលើកដំបូង។ បន្ទាប់មក វានឹងផ្ដល់ផលជារៀងរាល់ឆ្នាំតាមរដូវកាលរបស់វា គឺចាប់ផ្ដើមពី ខែកុម្ភៈ ដល់ ខែមេសា។ ពេលវេលាដ៏សំខាន់សម្រាប់ការថែទាំវាដើម្បីឱ្យទទួលបានផលល្អ គឺ ២-៣ខែ មុនចេញផ្កាដែលជាដំណាក់កាលលូតលាស់ត្រួយថ្មី និងដំណាក់កាលចេញផ្កាផ្លែ។ ក្នុងដំណាក់កាលសំខាន់ទាំងពីរនេះ កសិករត្រូវការដាក់ជីបំប៉នដើម កាត់សំអាតមែកងាប់ ជំរះស្មៅ កំចាត់សត្វល្អិតបំផ្លាញត្រួយនិងផ្កា

ធៀបនឹងបរិមាណចំណាយសរុប សមាមាត្រចំណាយរបស់សកម្មភាពធំៗ គឺ ការជំរះស្មៅ និងថែទាំ មានទំហំ ១១ ភាគរយ ចំណាយលើជីគីមីនិងជីធម្មជាតិ មានទំហំ ៤០ ភាគរយ ចំណាយលើថ្នាំពុល គីមីសំលាប់សត្វល្អិតមានទំហំ ១៥ ភាគរយ និងចំណាយលើការប្រមូលផលនិងដឹកជញ្ជូនទៅលក់មាន ទំហំ ៣៤ ភាគរយ។

*តារាងទី ១១៖ ជាតុចូល និងសមាមាត្រចំណាយនៃដំណាំស្វាយចន្ទីក្នុង (រៀល/ហាត)*

| ល.រ | សកម្មភាព | ចំណាយ (រៀល) | សមាមាត្រ (%) |
|---|---|---|---|
| ១ | ជីគីមី និងជីធម្មជាតិ | 605.225 | 40 |
| ២ | ថ្នាំពុលគីមីសំលាប់សត្វល្អិត | 226.228 | 15 |
| ៣ | ការថែទាំ និងជំរះស្មៅ | 162.246 | 11 |
| ៤ | ការប្រមូលផលនិងដឹកជញ្ជូនទៅលក់ | 50.4187 | 34 |
| | សរុប | 1.497.886 | 100 |

តម្រូវការជាតុចូលរបស់កសិករដាំស្វាយចន្ទី ត្រូវបានផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់ក្នុងភូមិ ឬមូលដ្ឋាន ចម្ការរបស់ខ្លួនតាមរបៀបអ្នកភូមិផងរបងជាមួយគ្នា ពោលគឺពួកគេទុកចិត្តគ្នាក្នុងការផ្តល់សេវាកម្លាំង ពលកម្ម ទិញជូរជំពាក់ និងពិភាក្សាពីដំណោះស្រាយផ្សេងៗតាមជំនាញ។ អ្នកផ្គត់ផ្គង់ ៥ ក្រុម ដែលធ្វើការប្រាស្រ័យទាក់ទងគ្នាក្នុងប្រតិបត្តិការដាំស្វាយចន្ទី។ រាល់ការទិញជូរវត្ថុធាតុដើមកសិកម្ម គឺ កសិករអាចទិញជំពាក់និងសងវិញនៅក្នុងរដូវប្រមូលផល។ ភាគីទាំងសងខាងមិនមានកិច្ចសន្យាជា លាយល័ក្សអក្សរនោះទេ ប៉ុន្តែគ្រាន់តែការកត់ត្រាទុកទាំងសងខាងនូវបរិមាណបំណុល។ កសិករទូទាត់ បំណុលរបស់ខ្លួនជាមួយអ្នកផ្គត់ផ្គង់ បន្ទាប់ពីទទួលបានចំណូលពីការលក់គ្រាប់ស្វាយចន្ទីភ្លាមៗ។ ក្រុម អ្នកផ្តល់សេវាអាចត្រូវបានទូទាត់ភ្លាមៗតាមការព្រមព្រៀងគ្នា ។ ក្រុមអ្នកផ្គត់ផ្គង់ទាំងនោះគឺ៖

ក. ក្រុមអ្នកលក់កូនស្វាយចន្ទី គឺ អាចជាកសិករដូចគ្នាជាប់ភូមិផងរបងជាមួយគ្នា និងជាអ្នកបណ្តុះ កូន និងតត្រួយកូនស្វាយចន្ទីនៅមូលដ្ឋានចម្ការរបស់កសិករ។ ក្រុមនេះអាចមានតែបណ្តុះកូន ចន្ទីពូជខ្មែរ សម្រាប់ឱ្យកសិករទិញយកទៅតត្រួយខ្លួនឯងពីពូជដែលចង់ដាំដូចជា ពូជអឹម២៣ ឬ ពូជអឹម០៩ ជាដើម។ ក្រុមនេះក៏អាចមានកូនស្វាយចន្ទីដែលតត្រួយពូជអឹម២៣ ឬ ពូជអឹម០៩ ជាស្រេច សម្រាប់កសិករយកទៅដាំចម្ការថ្មី ឬជួសដើមស្វាយចន្ទីដែលងាប់ក្នុងចម្ការចាស់។ ដូច្នេះ ការវិនិយោគលើការដាំកូនស្វាយចន្ទីក្នុងចម្ការថ្មីត្រូវពឹងលើជំនឿទុកចិត្តលើក្រុមអ្នកលក់ កូនស្វាយចន្ទីថាជាកូនពូជល្អតាមផែនការ។

ខ. ក្រុមអ្នកលក់ថ្នាំគីមីកំចាត់សត្វល្អិតក្នុងភូមិ។ ក្រុមនេះភាគច្រើនជាតូបលក់ថ្នាំគីមីកសិកម្ម ដែល មានច្បាប់អនុញ្ញាតិដែលបញ្ជាក់ពីសុវត្ថិភាព គុណភាព និងចំណេះដឹងក្នុងការប្រើប្រាស់ថ្នាំពុល។ ជាទូទៅ កសិករជឿទុកចិត្តអ្នកលក់ថ្នាំពុលអំពីប្រភេទថ្នាំទប់ទល់ប្រភេទសត្វល្អិតណាមួយ។

ក្រុមកសិករដែលចូលរួមពិភាក្សាបានឱ្យដឹងពីឃ្លាដែលពួកគាត់និយាយគ្នាថា «បាញ់ថ្នាំតាមចិនថា» គឺមានន័យថា ពួកគាត់ទិញថ្នាំពុលកសិកម្ម សម្រាប់សត្វល្អិតដែលបំផ្លាញស្វាយចន្ទីគាត់ទៅតាមតែអ្នកលក់ឱ្យយោបល់ ទោះថ្លៃប៉ុន្មានក៏មិនប្រកែកដែរ ឱ្យតែមានប្រសិទ្ធភាព។ ប៉ុន្តែជាក់ស្តែងវាមិនមានប្រសិទ្ធភាពដូចបំណងនោះទេ។ ព័ត៌មាននេះបញ្ជាក់ថា ទាំងកសិករនិងអ្នកផ្គត់ផ្គង់ថ្នាំពុល អាចមិនទាន់មានចំណេះដឹងអំពីថ្នាំពុល និងសត្វល្អិតស៊ីសង្វាក់គ្នា។ ជាពិសេសកសិករដែលបានជួបពិភាក្សាបានឱ្យដឹងថា ពួកគាត់មិនដែលបានទទួលចំណេះដឹងពីការធ្វើកសិកម្មច្រើននោះទេ។

គ. ក្រុមអ្នកលក់ជីគីមី។ ភាគច្រើននៃក្រុមនេះមានឃ្លាំងធំៗស្តុកជីគ្រាប់ប្រភេទដែលមានតម្រូវការដោយ កសិករដាំស្វាយចន្ទី។ រាល់ការទិញដូរជីគីមីកសិកម្មអាចភាគច្រើនជាការជំពាក់ ហើយទូទាត់នៅពេលលក់បានចំណូលក្នុងរដូវប្រមូលផល។

ឃ. ក្រុមអ្នកលក់កម្លាំងពលកម្ម។ ក្រុមនេះអាចមកពីបណ្តាភូមិឃុំឬខេត្តផ្សេងដែលមិនមានដំណាំជាន់រដូវថែទាំនិងប្រមូលផលស្វាយចន្ទី។ ក្រុមនេះអាចមានបទពិសោធន៍ ខាងដាំជម្រះសំអាតស្មៅ ពូនគល់ដំណាំ បាញ់ថ្នាំសម្រាប់សត្វល្អិត និងប្រមូលផលដំណាំសំខាន់ៗមួយចំនួនដូចជាដំឡូង ស្វាយចន្ទី ពោត សណ្តែក និងស្រូវ ហើយជួនកាលដំណាំកៅស៊ូទៀតផង។ ពួកគេគ្រាន់តែ ប្រមូលគ្នាតាមចំនួនតម្រូវការរបស់កសិករម្ចាស់ចម្ការ។

ង. ក្រុមអ្នកមានគ្រឿងយន្តកសិកម្ម។ ក្រុមនេះគឺជា អ្នកភូមិដែលមានលទ្ធភាពទិញគ្រឿងចក្រសម្រាប់ជួលភ្ជួររាស់ស្មៅ ពូនគល់ ជំនួសឱ្យក្រុមអ្នកលក់កម្លាំងពលកម្មខាងលើដែលអាចទៅរួច។ ការប្រើប្រាស់គ្រឿងយន្តកសិកម្មមាននិន្នាការកើនឡើងតិចតួច បើធៀបទៅនឹងដូចជាពោតសណ្តែក និងស្រូវ។ កសិករមិនអាចប្រើគ្រឿងចក្រឱ្យដាំកូនស្វាយចន្ទីដូចដាំ ពោត ឬសណ្តែកនោះទេ។ គ្រឿងចក្រអាចច្រូតស្រូវបាន ប៉ុន្តែមិនទាន់អាចប្រឡេះគ្រាប់ស្វាយចន្ទីពីផ្លែវាទេដោយហេតុថា គុណភាព គ្រាប់ស្វាយចន្ទីលក់បានថ្លៃឬថោក ទាក់ទងនឹងពណ៌សម្បុរនៃសំបកគ្រាប់ស្វាយចន្ទីនោះឯង។ ដូច្នេះដំណាំស្វាយចន្ទីនៅតែត្រូវកម្លាំងពលកម្មជាកម្មករច្រើនដដែល។

### ៤.៥.២ អ្នកផលិត

កសិករមួយចំនួនមានចម្ការស្វាយចន្ទីលើសពីមួយកន្លែង ដែលចម្ការនីមួយៗមានទំហំជាមធ្យមប្រហែល ២ហត។ កសិករចំនួន ១០០ភាគរយ មានចម្ការទីមួយដែលមានផ្ទៃជាមធ្យម ២,២៧ ហត ហើយពួកគេចំនួន ៤០ភាគរយ មានចម្ការទីពីរដែលមានទំហំប្រមាណ ២ហត។ ចំណែកឯកសិករចំនួន ៩ភាគរយមានចម្ការដល់ទីបី ដែលមានផ្ទៃជាមធ្យម ២,២៧ហត។ សរុបមក កសិករមានដីចម្ការជាមធ្យមប្រហែល ៣,២៧ហត ដែលអ្នកដែលមានដីតូចបំផុតគឺ ០,០៨ហត រហូតធំបំផុត ២៥ ហត។

*តារាងទី ១២៖ ផ្ទៃដីដាំចម្ការស្វាយចន្ទីដែលបានដាំ ឬកំពុងប្រមូលផល (ចំនួនគ្រួសារ ២៥០នាក់)*

| លរ | ចម្ការ | ចំនួនគ្រួសារ | អប្ប-អតិ (ហាត) | គិតជាមធ្យម (ហាត) |
|---|---|---|---|---|
| ១ | ចម្ការទី 1 (ហាត) | 100% | 0,08 – 15 | 2,27 |
| ២ | ចម្ការទី 2 (ហាត) | 40% | 0,20 – 10 | 2,00 |
| ៣ | ចម្ការទី 3 (ហាត) | 9% | 0,40 – 13 | 2,28 |
| | សរុបដីទាំងបីចម្ការ (ហាត) | 100% | 0,08 - 25 | 3,28 |

កសិករដាំស្វាយចន្ទីមានបទពិសោធន៍ដាំស្វាយចន្ទីចាប់ពី ២ឆ្នាំ រហូតដល់ ៥១ ឆ្នាំ ជាមធ្យម ពួកគាត់មានបទពិសោធន៍ប្រហែលជិត ១០ឆ្នាំ។ ពួកគេមានកម្លាំងពលកម្មសម្រាប់ដាំស្វាយចន្ទី ចាប់ពីម្នាក់ឯង រហូតដល់ ២៨ នាក់ រួមមានទាំងសមាជិកគ្រួសារនិងអ្នកស៊ីឈ្នួលដាំប្រមូលផល។ ជាមធ្យម កសិករគ្រួសារនីមួយៗមានគ្នាប្រហែល ៤,៤៦នាក់ ក្នុងនោះមានស្ត្រីពេញកម្លាំងពលកម្មពីម្នាក់ទៅ ៨ នាក់។ បើគិតជាមធ្យម គ្រួសារកសិករមានសមាជិកជាស្ត្រីប្រហែល ២,២២ នាក់។ ពួកគេក៏មានសមាជិកគ្រួសារ ដែលមានអាយុតិចជាង ១៨ឆ្នាំ ប្រហែល ២,៨១ នាក់ជាមធ្យម។

*តារាងទី ១៣៖ កម្លាំងពលកម្ម និងបទពិសោធន៍គ្រួសារដាំស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់)*

| លរ | កម្លាំងពលកម្ម | ចំនួន | អប្បបរិមា | អតិបរិមា | គិតជាមធ្យម |
|---|---|---|---|---|---|
| ១ | បទពិសោធន៍ដាំស្វាយចន្ទី | 250 | 2 | 51 | 9,52 |
| ២ | កម្លាំងពលកម្មជាស្ត្រី | 226 | 1 | 8 | 2,22 |
| ៣ | កម្លាំងពលកម្មអាយុក្រោម ១៨ឆ្នាំ | 64 | 1 | 9 | 2,81 |
| ៤ | កម្លាំងពលកម្មសរុប | 250 | 1 | 28 | 4,46 |

ក្នុងទំហំផ្ទៃដីសរុបជាមធ្យមប្រហែល ៣,២៧ហាត កសិករអាចប្រមូលផលស្វាយចន្ទីប្រហែល ២,៤២ហាតជាមធ្យម ដែលទទួលទិន្នផលប្រហែលសរុប ១.៨០០គក។ បើគិតជាទិន្នផលគ្រាប់ស្រស់នៃស្វាយចន្ទីជា ហិកតា កសិករទទួលបានតិចបំផុត គឺ ៥គក/ហាត និងខ្ពស់បំផុត ៤.៥០០គក/ហាត។ ដូច្នេះ កសិករទទួលបានជាមធ្យមនៃទិន្នផលគ្រាប់ស្រស់នៃស្វាយចន្ទី ៧៥០គក/ហាត។

ក្នុងមួយរដូវៗ គ្រួសារកសិករម្នាក់ៗអាចលក់គ្រាប់ស្វាយចន្ទីស្រស់បានចំណូលពី ៣៥.០០០ រៀលរហូតដល់ ១០៨ លានរៀល។ គិតជាមធ្យម គ្រួសារកសិករនីមួយៗអាចទទួលចំណូលដុលប្រហែល ១០ លានរៀល។ ការចំណាយលើការថែទាំនិងប្រមូលផល មានទំហំប្រហែល ៣ លានរៀល ជាមធ្យមក្នុងមួយគ្រួសារ ដែលនាំឱ្យគ្រួសារនីមួយៗអាចរកចំណេញសុទ្ធបានប្រហែល ៧,៥ លានរៀល។

ដដែកគ្នាពីទម្ងន់បាត់។ កូនកញ្ច្រែងអាចបង់ខាតដោយសារសែឡកាត់ទម្ងន់ក្រោយក្បៀស ឯសែឡអាចបង់ខាតដោយសារស្រកទម្ងន់ពីព្រោះពួកគាត់ស្តុកទុកយូរថ្ងៃ។ ដើម្បីទប់ទល់នឹងការស្រកទម្ងន់សែឡកំណត់ថាទម្ងន់ក្រោយក្បៀសត្រូវកាត់ចោលមិនទូទាត់ទេ ឯកូនកញ្ច្រែងទូទាត់ទាំងស្រុងឱ្យកសិករព្រោះទិញមួយថ្ងៃលក់មួយថ្ងៃ។ ឧទាហរណ៍ បើសិនជាមួយបាវមានទម្ងន់ ៧១,៨ គក សែឡកាត់យកនិងទូទាត់ត្រឹមតែ ៧១ គក ប៉ុណ្ណោះ ឯកូនកញ្ច្រែងទូទាត់ ៧១,៨ គក ទាំងស្រុងឱ្យកសិករ។ សែឡក៏មិនមានពេលត្រួតពិនិត្យគុណភាពលំអិតនោះទេ ពោលគឺ ទុកចិត្តពីការវាយតម្លៃរបស់កូនកញ្ច្រែងនិងកសិករ។

កូនកញ្ច្រែងលក់យកប្រាក់ចំណេញចាប់ពី ១០០ ទៅ ២០០រៀលក្នុង១គក ពេលលក់ទៅឱ្យសែឡនាំចេញទៅវៀតណាម។ ប្រាក់ចំណេញនេះអាចជួយឱ្យរួចដើមដោយសារទូទាត់ការបង់ខាតដោយការប្រែប្រួលតម្លៃប្រចាំថ្ងៃ និងការបាត់ទម្ងន់ ដូចការពន្យល់ខាងលើ។

*តារាងទី ១៥៖ លក្ខណៈរបស់អ្នកពាក់ព័ន្ធក្នុងខ្សែសង្វាក់គ្រាប់ស្វាយចន្ទីស្រស់*

| អ្នកផ្គត់ផ្គង់ធាតុចូល | អ្នកផលិត | អ្នកប្រមូលទិញ និងនាំចេញ |
|---|---|---|
| • ផ្តល់ព័ត៌មានពីធាតុចូលជាពិសេស ថ្នាំ និងជីកសិកម្មទៅតាមអ្វីដែលគេយល់ឃើញ ឬតៗគ្នា<br>• ពុំមានជំនាញ ដូចនេះគេមិនបានផ្តល់ព័ត៌មានឱ្យបានជាក់លាក់ដល់កសិករដែលមានបញ្ហា<br>• លក់ធាតុចូលសំខាន់ គឺថ្នាំសំលាប់ស្មៅ និងថ្នាំបំប៉ន<br>• ជួលគ្រឿងចក្រ និងលក់សេវាពលកម្មជួយថែទាំ និងប្រមូលផលស្វាយចន្ទី | • អនុវត្តការដាំដុះ តាមគ្នា<br>• ភាគច្រើនលក់ផលិតផលគ្រាប់ស្វាយចន្ទីស្រស់ចំណែកឯកសិករដែលលក់គ្រាប់ស្វាយចន្ទីស្ងួតមានតិច និងគ្មានបច្ចេកទេស<br>• ខ្វះខាតបច្ចេកទេសដាំដុះព្រោះមិនធ្លាប់ទទួលចំណេះដឹងថ្មីតាមវគ្គ បណ្តុះបណ្តាល<br>• នៅពេលស្វាយចន្ទីកើតជំងឺទៅរកថ្នាំពីអ្នកផ្គត់ផ្គង់ធាតុចូលតាមផ្សារយកមកព្យាបាល។<br>• ត្រូវតែលក់កសិផល ទោះជាខាតដោយថ្លៃដូរក្តី | • ជាកូនកញ្ច្រែងប្រមូលទិញពីកសិករ<br>• ជាសែឡនាំចេញគ្រាប់ស្វាយចន្ទីស្រស់<br>• សែឡពឹងផ្អែកតែលើទីផ្សារបរទេសតែមួយជាពិសេសវៀតណាម<br>• សែឡគ្មានបញ្ហានៅពេលតម្លៃចុះថោក ដោយសែឡប្តូរតម្លៃទិញថោកឱ្យកូនកញ្ច្រែង<br>• កូនកញ្ច្រែងជាអ្នកទទួលខាតពេលប្តូរ តម្លៃប្រចាំថ្ងៃ |

*ក្រាហ្វិកទី ៥៖ ខ្សែសង្វាក់នៃការផលិតនិងទិញលក់គ្រាប់ស្វាយចន្ទីស្រស់នៅខេត្តកំពង់ធំ និងកំពង់ចាម*

**អ្នកផលិត (កសិករ)**

លក់គ្រាប់ស្វាយចន្ទីស្រស់កូនកញ្ច្រែងក្នុងភូមិ ដែលមានតម្លៃមធ្យម ៦,០០០ រៀលក្នុង១គក (តម្លៃដើមរដូវ ៨,៥០០ រៀលក្នុងមួយគក និងចុងរដូវ ៨,៥០០ រៀលក្នុង១គក។

→

**កូនកញ្ច្រែងក្នុងភូមិ/ឃុំ**

ប្រមូលទិញគ្រា ប់ស្វាយចន្ទីស្រស់ពីកសិករដោយផ្ទាល់ ដោយត្រៀមខាត និងបំណេញ ៥០ ទៅ ១០០ រៀលក្នុង ១គក តាមការប្តូរថ្លៃប្រចាំថ្ងៃ និងការកាត់ទម្ងន់ក្រោយក្បៀសចោលដោយសៃឡូនាំចេញ ។

→

**ឈ្មួញកណ្តាលនៅផ្សារស្តី ចំការលើ**

ប្រមូលទិញគ្រាប់ស្វាយចន្ទីពីស្រុកសន្ទុក ខេត្តកំពង់ធំ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

→

**សៃឡូនាំទៅវៀតណាម នៅថ្លល់បែក**

ប្រមូលទិញគ្រាប់ស្វាយចន្ទីពីកម្ពុជា និងជាអ្នកកំណត់តម្លៃដល់ឈ្មួញកណ្តាលខ្មែរ និងកូនកញ្ច្រែងតាមភូមិ។ កាត់ទម្ងន់ក្រោយក្បៀសពីឈ្មួញកណ្តាលខ្មែរ និងកូនកញ្ច្រែងតាមភូមិ។

*ក្រាហ្វិកទី ៦៖ ខ្សែសង្វាក់នៃការផលិតនិងទិញលក់គ្រាប់ស្វាយចន្ទីស្រស់នៅខេត្តរតនគិរី*

**អ្នកផលិត (កសិករ)**

លក់គ្រាប់ស្វាយចន្ទីស្រស់កូនកញ្ច្រែងក្នុងភូមិ ដែលមានតម្លៃមធ្យម ៦.០០០ រៀលក្នុង១គក (តម្លៃដើម រដូវ ៨.៥០០ រៀលក្នុង១គក និងចុងរដូវ ៨.៥០០ រៀលក្នុង១ គក។

→

**កូនកញ្ច្រែងក្នុងភូមិ/ឃុំ**

ប្រមូលទិញគ្រាប់ស្វាយចន្ទីស្រស់ពីកសិករដោយផ្ទាល់ ដោយត្រៀមខាត និង បំណេញ ៥០ ទៅ ១០០ រៀលក្នុង ១គក តាមការប្តូរ ថ្លៃប្រចាំថ្ងៃ និងការកាត់ទម្ងន់ ក្រោយក្បៀសចោលដោយសៃឡូនាំចេញ។

→

**សៃឡូនាំទៅវៀតណាម**

ប្រមូលទិញគ្រាប់ស្វាយចន្ទីពីខេត្តរតនគិរី និងជាអ្នកកំណត់តម្លៃដល់ឈ្មួញកណ្តាលខ្មែរ និងកូនកញ្ច្រែងតាមភូមិ។ កាត់ទម្ងន់ក្រោយក្បៀសពី ឈ្មួញកណ្តាលខ្មែរ និងកូនកញ្ច្រែងតាមភូមិ។

## ៤.៦ ការប្រឈមចំពោះដំណាំស្វាយចន្ទី

### ៤.៦.១ ការប្រឈមដោយការប្រើពូជថ្មី

ពូជស្វាយចន្ទីពូជខ្មែរដែលកសិករធ្លាប់ដាំតពីជំនាន់មួយទៅជំនាន់មួយ ហើយមានបទពិសោធន៍គ្រប់គ្រាន់ ប្រឈមមុខនឹងបាត់បង់ពីទីផ្សារពាណិជ្ជកម្មគ្រាប់ស្វាយចន្ទី ដោយសារទំហំសាច់គ្រាប់តូច និងសំបកក្រាស់ ហើយវាជំនួសដោយពូជប្រភេទអឹម ដូចជា អឹម០៩ និងអឹម២៣ ជាដើម។ កសិករដែលមានចម្ការស្វាយចន្ទីពូជខ្មែរ ហើយចង់ដាំពូជថ្មីដោយគ្មានចម្ការផ្សេងនោះ ត្រូវតែសម្រេចចិត្តកាប់ចោលស្វាយចន្ទីពូជខ្មែរដែលមានអាយុកាលលើសពី ១០ឆ្នាំរបស់ខ្លួន ហើយកសិករត្រូវតែវិនិយោគទុនថ្មី និងរង់ចាំរហូតដល់ ៣ឆ្នាំ ទើបទទួលផលលើកដំបូង។

ការផ្លាស់ប្តូរពូជថ្មីនេះជាចរន្តនៃកសិកម្មទំនើប ហើយវាមិនអាចទប់ទល់បានឡើយ។ ប៉ុន្តែពូជថ្មីនោះ វានឹងជំនួសពូជចាស់ដោយរបៀបណា និងស្ថិតស្ថេររបៀបណានោះ វាអាស្រ័យដោយសមត្ថភាពទទួលយករបស់កសិករ និងទីផ្សារសេរី។ ការពិត ទីផ្សារសេរីជាកត្តាជម្រុញឱ្យមានការផ្លាស់ប្តូរពូជ ប៉ុន្តែចំណេះដឹងកសិករ គឺជាកត្តាសម្រេចជោគជ័យនៃការប្តូរពូជថ្មី។

ការសិក្សានេះបានរកឃើញថា កសិករដែលដាំពូជថ្មី ហាក់ដូចជាមិនបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសខ្សែសង្វាក់ពូជថ្មីនេះឱ្យបានគត់មត់នោះទេ។ ពួកគាត់ពិភាក្សាជាមួយកសិករដូចគ្នា និងអ្នកបណ្តុះកូនពូជថ្មី រួចសម្រេចចិត្តលើការវិនិយោគលើពូជថ្មី ដោយមិនបានសិក្សាលំអិតពីគុណសម្បត្តិ និងគុណវិបត្តិនោះទេ។ ការដាំដុះពូជថ្មីត្រូវបានជំនួយដោយអ្នកលក់កូនពូជថ្មី ឬអ្នកជួលគ្រឿងចក្រ ហើយការថែទាំត្រូវជំនួសដោយសេវាកម្លាំងពលកម្ម។ ការបែករំលែកការងារនេះអាចដូចជាមានភាពវិជ្ជមាន ដោយកសិករអាចដើរតួជាសហគ្រិនកសិកម្មតាមធនធានហិរញ្ញវត្ថុ ចំណេះដឹង និងបទពិសោធន៍របស់គាត់ដែលធ្លាប់មាន ។

ខណៈដែល កសិករហាក់មិនបានទទួលការបណ្តុះបណ្តាលពីខ្សែសង្វាក់ផលិតកម្មស្វាយចន្ទីពូជថ្មី កសិករសំដែងការខកចិត្តចំពោះអវត្តមានអ្នកជំនាញកសិកម្ម ឬស្ថាប័នកសិកម្មទាំងថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិក្នុងការជួយតម្រង់ទិសបច្ចេកទេសថ្មី។ កសិករហាក់ជួបជាមួយក្រុមហ៊ុនកសិកម្មក្នុងវិស័យឯកជនច្រើនជាងស្ថាប័នរដ្ឋ ក្នុងការផ្សព្វផ្សាយបច្ចេកទេសថ្មី ជាពិសេស ដំណាក់កាលពិសោធន៍ពូជថ្មី។ ជារឿយៗ កសិករបានផ្តល់ការសហការជាមួយក្រុមអ្នកស្រាវជ្រាវផ្នែកទីផ្សារ បញ្ហាសេដ្ឋកិច្ចសង្គម និងវិទ្យាសាស្ត្រជាច្រើនប្រធានបទ ប៉ុន្តែ កសិករមិនដែលបានទទួលមកវិញនូវចំណេះដឹងពីការស្រាវជ្រាវថ្មីដែលខ្លួនបានសហការនោះទេ។

កសិករមើលឃើញថា ស្ថាប័នកសិកម្មសាធារណៈហាក់ដូចជាប្រឹងវិនិយោគ ស្រាវជ្រាវ និងបណ្តុះបណ្តាលដល់កសិករខាងដំណាំស្រូវ ជាងដំណាំឧស្សាហកម្មដែលជាមុខព្រួញយ៉ាងសំខាន់មួយដែរ។ លើសពីនេះទៅទៀត វិស័យឯកជនដែលពាក់ព័ន្ធនឹងកសិកម្ម ព្រមទាំងការនាំចេញ ហាក់ទទួលរងសម្ពាធពីស្តង់ដាសុវត្ថិភាពស្បៀង និងភូតគាមអនាម័យ ដែលរិតត្បិតលើការផលិតនិងនាំចេញពីសំណាក់ស្ថាប័នជំនាញក្នុងស្រុកនិងប្រទេសដែលជាគោលដៅនាំចេញ។

កង្វះខាតនេះជម្រុញឱ្យបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មគ្រាប់ដំណាំសំខាន់ៗ និងការចូលរួមពីគ្រប់ស្ថាប័នជំនាញដែលពាក់ព័ន្ធ។ ការប្រាស្រ័យទាក់ទងក្នុងការចែករំលែកចំណេះដឹងពីកសិករទៅអ្នកស្រាវជ្រាវ គឺតែមានទៅវិញទៅមក និងចំពេលវេលានៃខ្សែសង្វាក់ផលិតកម្មដំណាំស្វាយចន្ទី។ ការពង្រឹងសមត្ថភាពស្ថានីយ៍ពិសោធន៍ និងបង្កើនទំនាក់ទំនងស្រែបង្ហាញពីស្រែពិសោធន៍ជាមួយនឹងកសិករ ជុំវិញនឹងអាចនាំឱ្យមានទស្សនៈវិជ្ជមាន និងការទទួលយកបច្ចេកវិទ្យាថ្មីដោយកសិករ ។

### ៤.៦.២ ការប្រឈមដោយសត្វល្អិតថ្មី

ការប្រឈមពីការបំផ្លាញដោយសត្វល្អិតនិងសត្វចង្រៃ បានធ្វើឱ្យកសិករជួបហានិភ័យបង់ខាតទ្វេរដង។ ហានិភ័យបង់ខាតទី១ គឺការបាត់បង់ទិន្នផលគ្រាប់ស្វាយចន្ទីយ៉ាងច្រើន ជួនកាលកសិករខ្លះបាត់បង់ទិន្នផលទាំងស្រុង។ ហានិភ័យបង់ខាតទី២ គឺ បង្កើនចំណាយច្រើនលើថ្នាំពុលកសិកម្មសម្រាប់កំចាត់សត្វល្អិត។

តាមការពិនិត្យមើលពីការប្រឈមរបស់កសិករដែលដាំស្វាយចន្ទីពូជខ្មែរ និងពូជអឹម២៣ បានឱ្យឃើញថា សត្វល្អិតនិងសត្វចង្រៃបំផ្លាញ ពិតជាការប្រឈមដ៏ធ្ងន់ធ្ងរ ដែលប៉ះពាល់ដល់ដំណាំស្វាយចន្ទី។ ចំណែកឯជំងឺរបស់ស្វាយចន្ទីដែលយាយីដល់ដំណាំនេះក៏ជាបញ្ហាប្រឈមទីពីរដែលកសិករជួប។




*ក្រាហ្វិកទី ៧៖ កត្តាប្រឈមលើដំណាំស្វាយចន្ទី (ចំនួនគ្រួសារ ២៥០នាក់)*

ចំពោះស្វាយចន្ទីពូជ អឹម២៣ រងការបំផ្លាញធ្ងន់ធ្ងរជាង ពូជស្វាយចន្ទីខ្មែរ ពីកត្តាសត្វល្អិតនិងសត្វចង្រៃ និងជំងឺ។ កសិករចំនួន ៤៤ភាគរយ ជួបសត្វល្អិតបំផ្លាញ និងប្រហែល ៧ភាគរយជួបជំងឺយាយីដំណាំស្វាយចន្ទីពូជអឹម២៣ របស់គាត់។ ចំណែកឯកសិករចំនួនប្រហែល ៣៣ភាគរយ ជួបសត្វល្អិតបំផ្លាញ និងប្រហែល ៥ភាគរយជួបជំងឺយាយីដំណាំស្វាយចន្ទីខ្មែររបស់គាត់។ ជាការកត់សំគាល់របស់កសិករ ក្នុងចម្ការតែមួយដែលមានពូជទាំងពីរដាំនៅក្បែរគ្នា ស្វាយចន្ទីពូជខ្មែរមិនមានការបំផ្លាញ

ពីសត្វល្អិតទេ។ កសិករបានទាញសន្និដ្ឋានដោយរបៀបគាត់ថា ពូជថ្មីប្រភេទអឹមអាចនឹងជាបច្ច័យដែលនាំឱ្យមានការទាក់ទាញសត្វល្អិតទាំងនោះ។

*តារាងទី ១៦៖ ទំហំនៃការជួបប្រទះបញ្ហារបស់ស្វាយចន្ទីតាមពូជ (ចំនួនគ្រួសារ ២៥០នាក់)*

| លរ | បញ្ហាប្រឈម | ពូជខ្មែរ | ពូជM23 | ពូជខ្មែរ | ពូជM23 |
|---|---|---|---|---|---|
| | | ចំនួន | | ភាគរយ | |
| ១ | គ្រោះធម្មជាតិ | 7 | 4 | 2,8 | 1,6 |
| ២ | សត្វល្អិតនិងសត្វចង្រៃ | 82 | 110 | 32,8 | 44 |
| ៣ | ជំងឺ | 12 | 14 | 4,8 | 5,6 |
| ៤ | លក់បានថោក | 2 | | 0,8 | |
| ៥ | មិនជួបបញ្ហា | 9 | 1 | 3,6 | 0,4 |
| | | 112 | 129 | 44,8 | 51,6 |

ការប្រឈមនេះត្រូវបានដោះស្រាយដោយជម្រើសប្រើថ្នាំពុល។ ដូច្នេះ វានឹងឆ្លុះបញ្ចាំងឱ្យឃើញពីចំណាយខ្ពស់ក្នុងការថែទាំ ទិន្នផលនិងគុណភាពទាបដែលទទួលបានពីដំណាំចម្ការនេះ។

## ៤.៦.៣ សត្វល្អិត មូសតែ

កសិករតែងជួបប្រទះសត្វល្អិតនិងជំងឺរបស់ស្វាយចន្ទីដដែលៗ តាមវដ្តនៃការលូតលាស់របស់ស្វាយចន្ទី។ ជំងឺដែលកើតពីពពួកចៃសរៗកើតលើស្លឹកនិងត្រួយខ្ចី និងសត្វដង្កូវរូងដើមនិងមែកតែងឬការប្រេះដើមហៀជ័រ បានបន្ថយាយីស្វាយចន្ទី នៅគ្រាប់ពូជនិងចម្ការរបស់គាត់។ តាមរយៈបទពិសោធន៍យូរឆ្នាំ និងការរៀនពីកសិករជិតខាង ពួកគាត់អាចទប់ស្កាត់បានចំពោះសត្វល្អិតប្រភេទនេះដោយប៉ះពាល់តិចតួចដល់ទិន្នផលនិងគុណភាពគ្រាប់ស្វាយចន្ទីរបស់គាត់។ ជម្រើសនៃការប្រើប្រាស់ថ្នាំពុល នាំឱ្យកសិករទទួលបានជោគជ័យ ប៉ុន្តែវាមានចំណាយខ្ពស់ក្នុងខ្សែសង្វាក់ផលិតកម្មរបស់កសិករ ។

ក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ កសិករដាំស្វាយចន្ទីជួបប្រទះការបំផ្លាញដោយសត្វល្អិតមួយប្រភេទថ្មី ដែលពួកគាត់ ហៅតគ្នាថា មូសតែ។ មូសតែ ហាក់នៅមិនទាន់មានឯកសារស្រាវជ្រាវបង្ហាញអតិសញ្ញាណដល់កសិករឡើយ។ មូសតែ បានគេប្រទះឃើញនៅប្រទេសផ្សេងៗដែលមានដំណាំស្វាយចន្ទី និងដំណាំតែ ដូចជា ប្រទេសឥណ្ឌា។




*រូបភាពទី ៤៖ មូសតែរាតត្បាតនៅដំណាំស្វាយចន្ទី និងដំណាំតែ*

តាមរយៈការកត់សំគាល់របស់កសិករខ្មែរ មូសតែ មានទំហំ រូបរាង និងហោះហើរ ស្រដៀងនឹងមូសដែកគោល។ កសិករជួបវានៅពេលវេលាខុសគ្នា ជួនកាលពេលព្រឹក ពេលថ្ងៃ និងពេលល្ងាច។ កសិករមិនទាន់ដឹងច្បាស់ថា មូសតែ បំផ្លាញត្រួយស្វាយចន្ទីដែលលាស់ថ្មីនៅខ្ចី ដោយរបៀបណានោះទេ គាត់គ្រាន់តែដឹងថា ស្លឹកនៃត្រួយស្វាយចន្ទីខ្ចីចាប់ផ្តើមខ្លោចជាដុំៗ ហើយស្រពោនងាប់ក្នុងមួយសប្តាហ៍បន្ទាប់ ហើយទងនៃត្រួយខ្ចីនោះក៏ងាប់បន្តបន្ទាប់ដែរ។ ស្វាយចន្ទីអាចចេញផ្កាផ្លែបានបន្ទាប់ពីត្រួយខ្ចីលាស់រឹងមាំ ហើយបើ មូសតែបំផ្លាញត្រួយនិងស្លឹកខ្ចីឱ្យងាប់ហើយនោះ កសិករនឹងមិនមាន ផលចន្ទីប្រមូលក្នុងរដូវវានេះទេ ព្រោះស្វាយចន្ទីជាដំណាំប្រកាន់រដូវ។



*រូបភាពទី ៥៖ ការបំផ្លាញត្រួយស្វាយចន្ទី ដោយមូសតែ នៅស្រុកស្ទឹងត្រង់ខេត្តកំពង់ចាម*

ដើម្បីទប់ទល់នឹងមូសតែនេះ កសិករមិនមានមធ្យោបាយជាក់លាក់ណាមួយឡើយ ហើយក៏មិនធ្លាប់ មានការណែនាំបង្ហាញពីស្ថាប័នជំនាញកសិកម្មដែរ។ ជម្រើសរបស់កសិករគឺ ការប្រើប្រាស់ថ្នាំពុលគីមី កសិកម្ម ដែលណែនាំដោយអ្នកលក់រាយ និងក្រុមហ៊ុនឯកជនថ្នាំពុលកសិកម្ម។

ថ្នាំពុលកសិកម្មដែលកសិករប្រើសម្រាប់កំចាត់មូសតែ មានច្រើនឈ្មោះទៅតាមការទុកចិត្តរបស់កសិករតាមយោបល់របស់អ្នកលក់ថ្នាំ ហើយវាខុសគ្នាពីកសិករមួយទៅមួយ ពីចម្ការមួយទៅចម្ការមួយ។ ពេលខ្លះកសិករលាយចម្រុះគ្នាច្រើនមុខ។ កសិករដែលបានចូលរួមក្រុមពិភាក្សា នៅឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បានឱ្យដឹងថា គាត់អាចបាញ់មួយខែពីរដង ប៉ុន្តែបើមានការបំផ្លាញខ្លាំង ពួកគាត់អាចបាញ់រហូតដល់មួយខែ ៤ដង។ ក្នុងមួយដងៗកសិករអាចចំណាយប្រហែល ១០០.០០០ រៀលក្នុង១ហិត ទាំងថ្លៃថ្នាំនិងសេវាអ្នកបាញ់ថ្នាំ។ ដូច្នេះ ពួកគាត់អាចចំណាយ ១លានរៀលក្នុង១ខែ ក្នុង១ហិត ដែលជាចំណាយដ៏ច្រើនក្នុងការទប់ទល់ មូសតែ។ កសិករខ្លះបានបោះបង់ចោលការព្យាយាម ព្រោះគាត់គិតថា បើគាត់នៅបន្តទប់ទល់ គាត់អស់ចំណាយកាន់ច្រើន ហើយរដូវផ្កាផ្លែកាន់តែជិតផុតទៅហើយ ដូច្នេះ ទិន្នផលពិតជាមិនអាចទូទាត់ចំណាយបានឡើយ។

សរុបសេចក្ដីមក មូសតែ កំពុងរាតត្បាតដំណាំស្វាយចន្ទីក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ។ វាធ្វើឱ្យងាប់ស្លឹកនិងត្រួយចន្ទីគ្រាប់ពូជ និងគ្រាប់ចម្ការ។ ជាពិសេស ចម្ការដែលមានពូជប្រភេទអឹមត្រូវបានបំផ្លាញធ្ងន់ធ្ងរជាងគេ។ កសិករកំចាត់មូសតែ ដោយបាញ់ថ្នាំចំរុះតាមអ្នកលក់ឱ្យយោបល់។ ក្នុងករណីធ្ងន់ធ្ងរ ចំណាយលើការបាញ់ថ្នាំ មានបរិមាណរហូតដល់រាប់លានរៀល ដែលធ្វើឱ្យកសិករខាងបង់ច្រើន និងពេលខ្លះកសិករបោះបង់ចោលចម្ការរបស់ខ្លួន ដោយសារមិនអាចទប់ទល់ឈ្នះ។ កសិករពុំទាន់ទទួលបានដំណោះស្រាយណាមួយគួរឱ្យទុកចិត្តពីស្ថាប័នជំនាញណាមួយឡើយ។ កសិករកំពុងរង់ចាំដំណោះស្រាយ ព្រោះកសិករបញ្ជាក់ថា ការបំផ្លាញដោយ មូសតែ ជាកត្តាស្លាប់រស់របស់ដំណាំចម្ការស្វាយចន្ទី មិនមែនតម្លៃនិងទីផ្សារស្វាយចន្ទីនោះទេ។

### ៤.៦.៤ បញ្ហាបាត់បង់ជីជាតិដី

កសិករក៏បានបញ្ជាក់ពីការយល់ឃើញរបស់គាត់ចំពោះការបាត់បង់ជីជាតិដីចម្ការរបស់គាត់ផងដែរ។ កត្តាបីសំខាន់ ដែលតែងជួបប្រទះនិងកំពុងផ្តល់ផលអវិជ្ជមានដល់ដំណាំកសិកម្មគ្រប់ប្រភេទគឺ ការកកើតស្មៅចង្រៃ ដីរឹងក្តាំង និងដីហូរច្រោះអស់ជីជាតិ។ ជាងពាក់កណ្តាលនៃកសិករដែលបានសំភាសន៍ទាំងអស់ (៥៧ ភាគរយ) ប្រាប់ថា ចម្ការរបស់គាត់មានស្មៅចង្រៃកើនឡើងខ្លាំងណាស់ហើយ ២០ភាគរយផ្សេងទៀតប្រាប់ថា ចម្ការគាត់មានស្មៅចង្រៃកើនឡើងជាមធ្យម។ ខណៈដែលកសិករ ២៩ភាគរយ ផ្សេងទៀតសំគាល់ឃើញថា ដីចម្ការគាត់រឹងក្តាំងជាមធ្យមនោះ យោបល់ពីដីហូរច្រោះអស់ជីជាតិពីចម្ការក៏មានកសិករ ២០ ភាគរយ បញ្ជាក់ដែរថា ដីហូរច្រោះអស់ជីជាតិ ក្នុងល្បឿនមធ្យម។

*តារាងទី ១៧៖ កត្តាប្រឈមផ្សេងៗធៀបនឹងការបំផ្លាញដោយសត្វល្អិត (ចំនួនគ្រួសារ ២៥០នាក់)*

| លរ | ការប្រឈម | កើនឡើង គិតជាភាគរយ | | | មិនកើនឡើង គិតជាភាគរយ | | |
|---|---|---|---|---|---|---|---|
| | | ខ្លាំង | មធ្យម | តិច | ខ្លាំង | មធ្យម | តិច |
| ១ | ការបំផ្លាញដោយសត្វល្អិត | 68 | 22 | 5 | | | |
| ២ | កកើតស្មៅចង្រៃ | 57 | 25 | 4 | | | |
| ៣ | ដីរឹងក្តាំង | 15 | 29 | 5 | 2 | | |
| ៤ | ដីហូរច្រោះអស់ជីជាតិ | 15 | 20 | 11 | | | |

តាមព័ត៌មានពីក្រុមកសិករចូលរួមពិភាក្សា បានឱ្យដឹងថា ដីចម្ការរបស់ពួកគាត់ បានប្រើប្រាស់ដាំដំណាំកសិកម្មប្រចាំរដូវ ឬប្រចាំឆ្នាំជាច្រើនមុខ ដូចជា ដាំដំឡូងឈើ សណ្តែក និងពោត ជាដើម ហើយទំរាំដល់ដំណាក់កាលដាំស្វាយចន្ទីសព្វថ្ងៃនេះ។ ការប្តូរពីដំណាំមួយទៅដំណាំមួយ ភាគច្រើនទាក់ទាញដោយតម្លៃទីផ្សារ។ ពួកគាត់សង្កេតឃើញថា ការប្រើជី និងថ្នាំពុលទៅតាមប្រភេទដំណាំកន្លងមក ហាក់ដូចជាធ្វើឱ្យដីចម្ការគាត់ខ្សោះជីជាតិ កែមិនឡើង។ ដំណាំស្វាយចន្ទី ដំណាំម្រេច និងដំណាំកៅស៊ូ ជាដំណាំ រើសដីនិងត្រូវការពេលវេលាយូរទើបបានផលមកវិញ។ បើសម្រេចចិត្តវិនិយោគដាំដំណាំទាំងនេះហើយ ដីចម្ការនោះនឹងមិនងាយអាចកែប្រែទៅរកភាពដើមបានឡើយ។

## *៤.៧ ការពិភាក្សា*

ការពិភាក្សានៅពេលនេះ គឺផ្តោតលើផ្នែកសំខាន់ៗនៃខ្សែសង្វាក់ផលិតកម្មដំណាំស្វាយចន្ទី គឺបច្ចេកទេសដាំពូជថ្មី បញ្ហាសត្វល្អិតបំផ្លាញ ជាពិសេសមូសតែ និងបញ្ហាតម្លៃទីផ្សារគ្រាប់ស្វាយចន្ទីស្រស់។ កត្តាទាំងបីនេះមានការជាប់ទាក់ទងគ្នា។ តម្លៃទីផ្សារសេរី គឺចាប់ពី ៤.០០០ ទៅ ១២.០០០ រៀល ក្នុង១គក ប៉ុន្តែបើគុណភាពគ្រាប់ស្វាយចន្ទីមិនត្រូវតាមការកំណត់ កសិករអាចលក់បានតម្លៃក្រោម ៤.០០០ រៀល ក្នុង១គក។ សំនួរដែលត្រូវការពិភាក្សារកដំណោះស្រាយគឺ ថាតើកសិករត្រូវដាំដំណាំស្វាយចន្ទីរបៀបណាដើម្បីឱ្យទទួលបានផលខ្ពស់ ហើយមានគុណភាពតាមតំលៃទីផ្សារ?

### *៤.៧.១ បច្ចេកទេសដាំពូជថ្មី*

តាមលទ្ធផលសិក្សាបង្ហាញថា កសិករបានទទួលយកពូជថ្មីប្រភេទអឹមចំពោះកសិករដែលមិនធ្លាប់ដាំ ឬដាំពូជប្រភេទអឹមនេះនៅចម្ការថ្មី។ រីឯកសិករដែលមានចម្ការស្វាយចន្ទីស្រាប់ ហើយជាចម្ការដែលដាំពូជខ្មែរនោះ ភាគច្រើននៃកសិករនោះបានកាប់ចោលស្វាយចន្ទីពូជខ្មែរទៅដាំពូជអឹមវិញ ដោយ

មានមូលហេតុទាក់ទាញមួយគឺ ពូជប្រភេទអឹម ផ្តល់គ្រាប់ដែលមានសំបកស្តើង និងសាច់គ្រាប់ធំ។ ប៉ុន្តែកសិករទាំងនោះ មិនបានសិក្សាពីគុណវិបត្តិមួយចំនួនទៀតនៃពូជប្រភេទអឹមនេះទេ។

គុណវិបត្តិធំមុនគេក្នុងដំណាក់កាលដាំដុះគឺ ចំណេះដឹងពីការដាំដុះនិងថែទាំពូជថ្មី។ កសិករដែលដាំពូជថ្មី ហាក់ដូចជាមិនបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសដាំដុះមុន និងក្រោយពេលប្រមូលផល ខ្សែសង្វាក់ផលិតកម្មពូជថ្មីនេះឡើយ។ ការសម្រេចចិត្ត គឺធ្វើឡើងដោយពិភាក្សាជាមួយកសិករដូចគ្នា និងជាពិសេស អ្នកបណ្តុះកូនពូជថ្មី រួចចាប់វិនិយោគលើចម្ការពូជថ្មី។ ខណៈដែលកសិករហាក់មិនមានមធ្យោបាយទទួលចំណេះដឹងពីខ្សែសង្វាក់ផលិតកម្មស្វាយចន្ទីពូជថ្មី អ្នកជំនាញ ឬស្ថាប័នកសិកម្មទាំងថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ក៏មិនសូវជាបានប្រាស្រ័យទាក់ទងគ្នានោះទេ។ ផ្ទុយទៅវិញ ក្រុមហ៊ុនកសិកម្មក្នុងវិស័យឯកជន ហាក់ដូចជាដើរតួសំខាន់ក្នុងខ្សែសង្វាក់ផលិតកម្មដំណាំនេះ។

វិបត្តិខាងលើនេះ ជម្រុញឱ្យបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសដាំដុះស្វាយចន្ទី និងពង្រឹងការងារពិសោធន៍ស្រាវជ្រាវរកដំណោះស្រាយចំពោះការប្រឈមថ្មីៗ ដោយមានការចូលរួមពីគ្រាប់ស្ថាប័នជំនាញដែលពាក់ព័ន្ធ ទាំងវិស័យសាធារណៈ និងក្រុមហ៊ុនឯកជន។

### ៤.៧.២ បញ្ហាសត្វល្អិតបំផ្លាញ និង មូសតែ

គុណវិបត្តិធំបំផុតមួយទៀតគឺ ដែលកសិករកំពុងជួបប្រទះសត្វល្អិតបំផ្លាញលើពូជប្រភេទអឹមខ្លាំងជាងស្វាយចន្ទីពូជខ្មែរ។ កសិករជិតពាក់កណ្តាលនៃអ្នកដែលបានសំភាសន៍ ជួបសត្វល្អិតបំផ្លាញលើដំណាំស្វាយចន្ទីពូជអឹម២៣ ឯកសិករចំនួនមួយភាគបី ជួបសត្វល្អិតបំផ្លាញលើដំណាំស្វាយចន្ទីខ្មែរ។ ដូច្នេះ វាអាចទាញសន្និដ្ឋានបានថា ពូជថ្មីប្រភេទអឹមអាចនឹងជាបច្ច័យដែលនាំឱ្យមានការទាក់ទាញសត្វល្អិតទាំងនោះ។ ដំណោះស្រាយ គឺការប្រើប្រាស់ថ្នាំពុល កម្ចាត់មិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។ ជាលទ្ធផល កសិករបានចំណាយថវិកាខ្ពស់ក្នុងការថែទាំ និងទទួលបានទិន្នផលទាប។ ដូច្នេះ ការបំផ្លាញដោយសត្វល្អិតចង្រៃ បានធ្វើឱ្យកសិករជួបហានិភ័យបង់ខាតទ្វេដង គឺទិន្នផលធ្លាក់ចុះ ឬបាត់បង់ទិន្នផលទាំងស្រុង ហើយត្រូវបង់ចំណាយខ្ពស់លើថ្នាំពុលកសិកម្មសម្រាប់កំចាត់សត្វល្អិតនោះ។

សត្វល្អិតដែលគួរឱ្យចាប់អារម្មណ៍ជាងគេ ហើយបង្កហានិភ័យខ្លាំងជាងគេ គឺ មូសតែ។ កសិករក្នុងស្រុក និងស្ថាប័នជំនាញ ហាក់នៅមិនទាន់យល់ដឹងស៊ីសង្វាក់គ្នាពីអត្តសញ្ញាណ និងការបំផ្លាញពីមូសតែនេះទេ។ មូសតែ បានគេប្រទះឃើញនៅប្រទេសផ្សេងៗដែលមានដំណាំស្វាយចន្ទី និងដំណាំតែពិសេសនៅប្រទេសឥណ្ឌាជាច្រើនឆ្នាំហើយ។ ប៉ុន្តែ កសិករខ្មែរ ដែលទទួលយកស្វាយចន្ទីពូជប្រភេទអឹម ជួបប្រទះការបំផ្លាញដោយសត្វល្អិតមួយប្រភេទថ្មីនេះ ក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ។

កសិករខ្មែរ គ្រាន់តែអាចសំគាល់បានថា មូសតែ មានទំហំ រូបរាង និងហោះហើរ ស្រដៀងនឹងមូសដែកគោល ហើយកសិករខ្មែរមិនទាន់ដឹងច្បាស់ថា វាបំផ្លាញស្វាយចន្ទី ដោយរបៀបណានោះទេ។

តាមកំណត់ត្រាមូសតែ ដែលបំផ្លាញចម្ការតែ គឺវាបឺតជញ្ជក់ទងខ្ចី និងស្លឹកនៃត្រួយខ្ចីរបស់ដើមតែ និងក្រោយមកត្រួយតែ ប្រែក្រៀមស្វិតមិនអាចប្រមូលផលបាន។ ដូចគ្នានេះដែរ កសិករខ្មែរ គ្រាន់តែសំគាល់ថា ស្លឹកនៃត្រួយស្វាយចន្ទីខ្ចីចាប់ផ្តោមខ្លោចជាដុំៗ ហើយស្រពោនងាប់ក្នុងមួយសប្តាហ៍បន្ទាប់ ហើយទងនៃត្រួយខ្ចីនោះក៏ងាប់បន្តបន្ទាប់ មិនអាចចេញផ្កា និងផ្លែបានក្នុងរដូវនោះទេ។

ជម្រើសរបស់កសិករក្នុងការប្រើប្រាស់ថ្នាំពុលគីមីកសិកម្ម ដែលណែនាំដោយអ្នកលក់រាយ និងក្រុមហ៊ុនឯកជនថ្នាំពុលកសិកម្ម បានជួយទប់ស្កាត់មានប្រសិទ្ធិភាពតាមកម្រិតបំផ្លាញរបស់វា។ ប៉ុន្តែកសិករក៏ជួបចំណាយខ្ពស់ដែរ ដោយសមត្ថភាពទប់ទល់បានត្រូវបន្តបាញ់មួយខែពីរដង រហូតដល់មួយខែ៤ដង។ ក្នុងរយៈពេល ២ ទៅ ៣ខែ នៃដំណាក់កាលផ្ការបស់ស្វាយចន្ទី ពីខែធ្នូ ដល់ខែមីនា កសិករអាចចំណាយប្រហែល ១លានរៀល ក្នុង១ខែ ក្នុង១ហត ដែលជាចំណាយដ៏ច្រើនធៀបនឹងចំណូលពីការលក់ក្នុង ១ហត។ ក្នុងកម្រិតបំផ្លាញខ្លាំង កសិករខ្លះបានបោះបង់ចោលការព្យាយាម ចម្ការស្វាយចន្ទីរបស់គាត់អាចបាត់បង់ទិន្នផលទាំងស្រុងក្នុងរដូវកាលមួយនេះ ហើយកសិករថែមទាំងត្រូវទូទាត់ការចំណាយកន្លងមកទៀត។

សរុបសេចក្តីមក មូសតែ កំពុងរាតត្បាតដំណាំស្វាយចន្ទីក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះហើយ កសិករកំពុងរងចាំដំណោះស្រាយ ព្រោះកម្រិតនៃការបំផ្លាញរបស់ មូសតែ ជាកត្តាស្លាប់រស់របស់ដំណាំចម្ការស្វាយចន្ទី។

### ៤.៧.៣ បញ្ហាតម្លៃទីផ្សារគ្រាប់ស្វាយចន្ទី

នៅប្រទេសកម្ពុជា ផលិតផលដែលទទួលបានពីចម្ការស្វាយចន្ទីគ្រាប់ពូជទាំងអស់ គឺមានតែគ្រាប់ស្វាយចន្ទីមួយមុខតែប៉ុណ្ណោះ។ នៅប្រទេសឥណ្ឌា សាច់នៃផ្លែស្វាយចន្ទីស្រស់ អាចគៀបយកទឹកដើម្បីផលិតជាភេសជ្ជៈនិងគ្រឿងស្រវឹងពីរបីប្រភេទ។ គ្រាប់ស្វាយចន្ទីនៅប្រទេសកម្ពុជា ត្រូវបានលក់ស្រស់ និងនាំចេញទៅប្រទេសវៀតណាម។ គ្រាប់ស្វាយចន្ទីនៅខេត្តរតនគិរីដែលជាខេត្តជាប់ព្រំប្រទល់ប្រទេសវៀតណាមបានដឹកនាំចេញទៅវៀតណាម។ ចំណែកឯគ្រាប់ស្វាយចន្ទីនៅខេត្តកំពង់ធំ និងកំពង់ចាមដែលមានភូមិសាស្ត្រនៅចំកណ្តាលប្រទេសកម្ពុជា ក៏បានដឹកនាំចេញទៅវៀតណាមដែរ។

គ្រាប់ស្វាយចន្ទីត្រូវបានលក់ជាគ្រាប់ស្រស់ ហើយតម្លៃរបស់វាគឺអាស្រ័យតាមគុណភាព និងពេលវេលាលក់នៅដើមឬចុងរដូវប៉ុណ្ណោះ។ បើគ្រាប់ស្វាយចន្ទីពូជប្រភេទអឹម មានសម្បុរល្អ និងសាច់ណែន ហើយទទួលបានដើមរដូវ គឺមានតម្លៃ ៨.៥០០រៀលក្នុង១គក និងតម្លៃចុងរដូវគឺ ៤.០០០រៀលក្នុង១គក នឹងអាចធ្លាក់ដល់ ២.០០០រៀលក្នុង១គក។ ជាមធ្យម កសិករអាចលក់បាន នៅរដូវសម្បូណ៌គ្រាប់ស្វាយចន្ទីស្រស់ គឺ ៦.០០០រៀលក្នុង១គក វាជាតម្លៃដែលកសិកររំពឹងទុកជារៀងរាល់ឆ្នាំ។

តម្លៃគ្រាប់ស្វាយចន្ទីស្រស់ប្រែប្រួលយ៉ាងហោចណាស់ ២ដងក្នុងមួយថ្ងៃផងដែរ ដោយសារមូលហេតុមិនច្បាស់លាស់ដែលអាចដឹងមុនបាន។ ទំហំថ្លៃដែលប្រែប្រួលគឺ ឡើងឬចុះ ចាប់ពី ៥០ - ១០០រៀលក្នុង១គក។ ការប្រែប្រួលនេះបានបង្កឱ្យបង់ខាតដល់ឈ្មួញតូចៗដែលហៅថា កូនកញ្ច្រែង

ជាអ្នកប្រមូលទិញផ្ទាល់តាមភូមិ ដោយហេតុថា ឈ្មួញនាំចេញ ហៅថា សៃទ្បូ ទូទាត់ជាមួយ តម្លៃថ្មី លើបរិមាណដែលឈ្មួញតូចៗបានទិញរួចហើយ។ កត្តាលើកទឹកចិត្តដល់ឈ្មួញតូចៗឱ្យបន្តប្រមូលទិញ គឺប្រាក់ចំណេញចាប់ពី ១០០ ទៅ ២០០រៀលក្នុង១គក ពេលលក់ទៅឱ្យឈ្មួញនាំចេញ។ ថ្ងៃខ្លះប្រាក់ចំណេញនេះអាចជួយឱ្យរួចដើម ដោយសារទូទាត់ការបង់ខាតដោយការប្រែប្រួលតម្លៃប្រចាំថ្ងៃ ថ្ងៃខ្លះទៀតប្រាក់ចំណេញនេះអាចសល់តែពាក់កណ្ដាលព្រោះការទូទាត់ការបាត់ទម្ងន់។

ការប្រែប្រួលតម្លៃនេះមានផលវិបាកផ្សេងៗគ្នាលើឈ្មួញគ្រប់បណ្ដាញនិងកសិករ។ ជាទូទៅសៃទ្បូនាំចេញ ទទួលបានអត្ថប្រយោជន៍ពីការប្រែប្រួលតម្លៃនេះជាងគេ ដោយហេតុថា សៃទ្បូអាចទម្លាក់ថ្លៃឱ្យឈ្មួញកណ្ដាល និងកូនកញ្ជ្រែងទិញតម្លៃទាប ដើម្បីខ្លួនអាចរក្សាបានចំណេញពីការនាំចេញរបស់ខ្លួន។ ការគ្រប់គ្រងតម្លៃរបៀបនេះ បង្ហាញពីចរិកទីផ្សារសេរីប្រចាំថ្ងៃអនុវត្តន៍ដោយមិនមានកិច្ចសន្យាប្រចាំថ្ងៃ ហើយវាក៏មិនមានការសម្របសម្រួលពីអាជ្ញាធរជំនាញណាមួយឡើយ។ កសិករជាអ្នករងគ្រោះដោយលក់កសិផលបានថោក ហើយឈ្មួញកណ្ដាល និងកូនកញ្ជ្រែង អាចប្រឈមនឹងការបង់ខាតជាញឹកញយ។

សរុបសេចក្ដីមក កត្តាទាំងបីដែលបានពិភាក្សាខាងលើ ពិតជាមានឥទ្ធិពលអវិជ្ជមានដល់ខ្សែសង្វាក់ផលិតកម្មស្វាយចន្ទីនៅប្រទេសកម្ពុជា។ ប៉ុន្តែ កត្តាជាអាយុជីវិតនៃដំណាំនេះ គឺ ការបំផ្លាញដោយមូសតែ ដែលទាមទារឱ្យមានដំណោះស្រាយជាបន្ទាន់។

## ៥. សន្និដ្ឋាន និងអនុសាសន៍

ការសិក្សាពីខ្សែសង្វាក់ផលិតកម្មដំណាំស្វាយចន្ទីនៅប្រទេសកម្ពុជា បានធ្វើឡើងក្នុងខេត្តចំនួនបីគឺ កំពង់ចាម កំពង់ធំ និងរតនគិរី។ កសិករដាំស្វាយចន្ទី ២៥០គ្រួសារដែលដាំដុះស្វាយចន្ទី និងធ្លាប់ប្រមូលផលចន្ទីចាប់ពីម្ដងឡើងទៅត្រូវសំភាសន៍។ ការសិក្សានេះមានគោលបំណង ១) ដើម្បីកំណត់ពីបញ្ហាប្រឈមនានា របស់អ្នកពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់ផលិតកម្មស្វាយចន្ទី ២) ដើម្បីស្វែងរកនូវដំណោះស្រាយដែលសមស្របក្នុងការធានាបាននូវផលប្រយោជន៍របស់អ្នកពាក់ព័ន្ធទាំងអស់ និង ៣) ដើម្បីកំណត់ពីតម្រូវការបច្ចេកទេសរបស់អ្នកពាក់ព័ន្ធក្នុងខ្សែសង្វាក់ផលិតកម្មដើម្បីឱ្យស្ថាប័នជំនាញអាចជួយអន្តរាគមន៍បានប្រកបដោយប្រសិទ្ធភាព។ ការសិក្សាបានបង្ហាញពីលទ្ធផលសំខាន់ៗដូចខាងក្រោម៖

- កសិករដាំស្វាយចន្ទីចំនួន ២៥០ នាក់ មានជាងពាក់កណ្ដាលជាប្ដី និងជិតពាក់កណ្ដាលទៀតជាប្រពន្ធនៃគ្រួសារកសិករដែលមានសំភាសន៍។ គ្រួសារនីមួយៗមានគ្នាជាមធ្យម ៤,៨៦ នាក់ ដែលមានសមាជិកស្ត្រីជាមធ្យមមាន ២,៣២ នាក់ និងអ្នកដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅមាន ៣,១៦ នាក់។ កសិករដែលបានសំភាសន៍ទាំងនោះភាគច្រើនរស់នៅក្នុងមូលដ្ឋាននោះតាំងពីកំណើត ហើយ ៩៨ភាគរយជាធ្វើចម្ការ ៤១ ភាគរយ ទៀតធ្វើស្រែ និង ១៤ភាគរយទៀតលក់ដូរកំប៉ិចកំប៉ុកបន្ថែម។

- ការដាំដំណាំស្វាយចន្ទីហាក់ចាប់ផ្តើមឃ្លាតពីទម្លាប់ដើមបន្តិចម្តងៗ ដោយសារតែកត្តាតម្រូវការទីផ្សារ ពូជថ្មី និងការប្រែប្រួលអាកាសធាតុ។ កសិករបានប្រើប្រាស់គ្រឿងចក្រជំនួសកម្លាំងពលកម្មតាមតែអាចទៅរួច។ កសិករកំពុងប្រើពូជស្វាយចន្ទីប្រភេទពូជអឹម០៩ ពូជអឹម២១ ពូជអឹម២៣ និងពូជស្វាយចន្ទីប្រពៃណីខ្មែរ។ និន្នាការប្តូរពីចម្ការពូជស្វាយចន្ទីប្រពៃណីខ្មែរទៅដាំពូជអឹម កាន់តែកើនឡើងដោយសារពូជប្រភេទអឹម មានសំបកស្តើងនិងសាច់គ្រាប់ធំ។ ទិន្នផលជាមធ្យមក្នុងចំណោមកសិករទាំង ២៥០ គ្រួសារដែលសំភាសន៍ គឺ ៧៥០គក ក្នុង១ហត ប៉ុន្តែក៏មានកសិករមួយចំនួនទទួលបានទិន្នផលរហូតដល់ ៤.៥០០គកក្នុង១ហតដែរ។
- កសិករ ៣៩ភាគរយ យល់ថា ទិន្នផលកើនឡើង ហើយកសិករ ៣១ភាគរយ យល់ថាទិន្នផលនៅដដែល រីឯកសិករ ៣០ភាគរយទៀត យល់ថា ទិន្នផលធ្លាក់ចុះ។
- កសិករប្រហែល ៤ភាគរយ នឹងបោះបង់ចោលការដាំដំណាំស្វាយចន្ទីនេះ មូលហេតុគឺ ការជួបប្រទះនឹងបញ្ហាប្រឈមគ្រោះធម្មជាតិ និងការកាន់តែបន្តកើនឡើងនៃការរាតត្បាតរបស់សត្វល្អិតបំផ្លាញ ការប្រែប្រួលតម្លៃលក់ពេលប្រមូលផល ការខ្វះខាតកម្លាំងពលកម្ម និងឥណទានសម្រាប់ផលិតកម្ម ។
- ទីផ្សារគ្រាប់ស្វាយចន្ទីនៅតំបន់ដែលបានសិក្សា គឺពឹងលើទីផ្សារប្រទេសវៀតណាម។ គ្រាប់ស្វាយចន្ទីស្រស់ត្រូវបានប្រមូលទិញដោយបណ្តាឈ្មួញ និងអ្នកនាំចេញ ឬ សៃឡូទៅប្រទេសវៀតណាម។
- តាមរយៈសៃឡូដែលអាចជាច្រកនាំចេញក្រៅប្រទេស តម្លៃលក់ចេញទិញចូលដោយឈ្មួញកណ្តាលហាក់ត្រូវបានគ្រប់គ្រងដោយបណ្តាញសៃឡូទាំងនោះ។ ឈ្មួញកណ្តាល និងប្រមូលទិញតូចៗទទួលបានប្រាក់ចំណេញតិចតួច ឯកសិករវិញលក់កសិផលរបស់ខ្លួនបានថោកស្មើរគ្រាប់រដូវ។ តម្លៃគ្រាប់ស្វាយចន្ទីស្រស់ខ្ពស់បំផុតនៅដើមរដូវ គឺ ៨.៥០០រៀលក្នុង១គក និងតម្លៃចុងរដូវគឺ ៤.០០០រៀលក្នុង១គក។ ជាមធ្យម កសិករអាចលក់បាននៅរដូវសម្បូណ៌គ្រាប់ស្វាយចន្ទីស្រស់ គឺ ៦.០០០រៀលក្នុង១គកនៅឆ្នាំ ២០១៧ ដែលជាតម្លៃដែលកសិកររំពឹងទុកជារៀងរាល់ឆ្នាំ។ និន្នាការនៃការប្រែប្រួលតម្លៃគ្រាប់ស្វាយចន្ទីស្រស់ក្នុងរយៈពេល បីឆ្នាំជាប់គ្នា ពី ២០១៤ ដល់ ២០១៦ បង្ហាញតម្លៃមធ្យមនៅពាក់កណ្តាលរដូវបន្តកើនឡើង ១.០០០ រៀល ជារៀងរាល់ឆ្នាំ ពី ៣,៥០០ រៀល ឆ្នាំ ២០១៤ ទៅ ៤.៥០០ រៀល ឆ្នាំ២០១៥ និង ៥.៥០០ រៀល ឆ្នាំ២០១៦។
- កសិករអាចទទួលបានប្រាក់ចំណូលដុលពីការលក់ស្វាយចន្ទីប្រហែល ៤,៣ លានរៀល/ហត និងចំណាយប្រហែល ៤៥ ម៉ឺនរៀល/ហត។ ដូច្នេះ កសិករអាចរកចំនេញសុទ្ធក្នុងមួយឆ្នាំៗ ប្រហែល ៣,៩ លានរៀល/ហត។
- ក្នុងចំណោមធាតុចូលកសិកម្មទាំងអស់ ចំណាយលើថ្នាំពុលគឺមីសំលាប់សត្វល្អិតមានទំហំជាមធ្យម ១៥ ភាគរយ នៃខ្ទង់ចំណាយសរុប ឬបរិមាណ ២២០.០០០រៀល/ហត ហើយវាមិន

អាចកំណត់បាន ព្រោះវាអាស្រ័យទៅលើកម្រិតបំផ្លាញរបស់សត្វល្អិត ជាពិសេសសត្វល្អិតថ្មី ដែលកសិករស្គាល់ថាជា មូសតែ។ ក្នុងកម្រិតបំផ្លាញខ្លាំង ចំណាយលើថ្នាំកំចាត់សត្វល្អិតឡើងរហូតដល់ ១ ទៅ ២ លានរៀល/ហត។

- ការវេចខ្ចប់គ្រាប់ស្វាយចន្ទី គឺ ជាការច្រកបេ ឬបាវ ចំណុះប្រហែល ៧០-៨០ គក រួចជាស្រេចដោយកសិករ។ ភាពស្មោះត្រង់របស់កសិករគឺជារឿងសំខាន់ណាស់ នៅក្នុងការច្រកគ្រាប់ស្វាយចន្ទីតាមគុណភាពកំណត់។
- ការប្តូរយកពូជស្វាយចន្ទីថ្មីមកដាំ គឺជាចរន្តមិនអាចជៀសរួចពីព្រោះតែទីផ្សារទាក់ទញ។ ប៉ុន្តែកសិករត្រូវមានផែនការដាំដុះ ចំណេះដឹង និងត្រៀមបញ្ចៀសហានិភ័យនៃការវិនិយោគលើចម្ការពូជថ្មីនេះ។
- ការទទួលយកពូជថ្មីប្រភេទអឹម ធ្វើឱ្យកសិករប្រឈមនឹងការរៀនសូត្របច្ចេកទេសដាំដុះថ្មី និងកសិករប្រឈមនឹងសត្វល្អិតថ្មីដែលបំផ្លាញទិន្នផលយ៉ាងធ្ងន់ធ្ងរ។ កង្វះខាតនេះជម្រុញឱ្យបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មគ្រប់មុខដំណាំសំខាន់ៗ និងការចូលរួមពីគ្រប់ស្ថាប័នជំនាញដែលពាក់ព័ន្ធ។
- ការបាត់បង់ជីជាតិដីចម្ការ ការកកើតស្មៅចង្រៃ ដីរឹងក្តាំង និងដីហូរច្រោះអស់ជីជាតិ គឺបញ្ហាដែលជួបប្រទះយ៉ាងរាំរ៉ៃសម្រាប់គ្រប់កសិករ និងគ្រប់ចម្ការដំណាំ មិនមែនលើតែដំណាំស្វាយចន្ទី។ ការប្តូរពីដំណាំមួយទៅដំណាំមួយ ភាគច្រើនទាក់ទាញដោយតម្លៃទីផ្សារ ហើយការប្រើជីគីមី និងថ្នាំពុលទៅតាមប្រភេទដំណាំកន្លងមកហាក់មិនបានអនុលោមតាមបទដ្ឋានបច្ចេកទេសដាំដុះដំណាំឡើយ។

ដើម្បីរួមចំណែកទៅនឹងដំណោះស្រាយ ដូចបានលើកឡើងនៅក្នុងគោលបំណងនៃការសិក្សាខាងលើការសម្របសម្រួល និងគោលនយោបាយគាំទ្រផលិតកម្មស្វាយចន្ទី គួរគប្បីផ្តោតលើចំណុចខាងក្រោម៖

- ជម្រុញលើកទឹកចិត្តក្រុមហ៊ុនឯកជនវិនិយោគលើសិប្បកម្ម និងរោងចក្រកែច្នៃគ្រាប់ស្វាយចន្ទីក្នុងស្រុកថែមទៀតនិ ងពិចារណាលើការកែច្នៃអនុផលផ្លែ ដូចជាការផលិតទឹកផ្លែឈើ ឬស្រាសាប៊ូជាដើម។ ការដែលមានការកែច្នៃក្នុងស្រុកអាចជួយឱ្យមានស្ថេរភាពតម្លៃគ្រាប់ស្វាយចន្ទីស្រស់ ឬក៏អាចបង្កើនតម្លៃទីផ្សារសេរីដែលប្រកួតប្រជែងពីដៃគូច្រើន។ វាក៏អាចជួយឱ្យកសិករពន្យាអាយុចម្ការចាស់ និងបន្តស្រូបយកប្រាក់ចំណូលពីចម្ការនោះ ទោះជាពូជស្វាយចន្ទីនៃចម្ការចាស់នេះមិនអាចមានតម្រូវការដោយទីផ្សារក្រៅប្រទេសក៏ដោយ។ ទីផ្សារនៃរោងចក្រកែច្នៃក្នុងស្រុកក៏អាចផ្តល់ជាតម្លៃបន្ថែម និងការងារដល់កម្មករក្នុងប្រទេសផងដែរ។
- ស្ថាប័នជំនាញត្រូវបន្តពង្រឹងការស្រាវជ្រាវនិងផ្សព្វផ្សាយលើពូជថ្មីដែលកសិករទទួលយក តាមតម្រូវការទីផ្សារក្រៅប្រទេស។ បច្ចេកទេស និងការថែទាំដែលអស់ចំណាយតិចនឹងជួយបង្កើន

ចំណូលដល់កសិករជាអ្នកផលិត។ ការបណ្តុះបណ្តាលពីប្រើប្រាស់ជី និង ថ្នាំពុលកំចាត់សត្វល្អិតបំផ្លាញ ពិតជាចាំបាច់សម្រាប់កសិករដាំពូជថ្មី។

- ស្ថាប័នជំនាញគួរស្វះស្វែងជួយកសិករដាំស្វាយចន្ទីជាបន្ទាន់ ក្នុងការទប់ស្កាត់ការបំផ្លាញពីសត្វល្អិតប្រភេទថ្មី គឺ មូសតែ ដែលទើបរាតត្បាតក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ។ ការយល់ច្បាស់ពីកាយសិរីរៈវិទ្យា ជីវសាស្ត្រ និងទម្លាប់រស់នៅរបស់មូសតែ អាចជួយឱ្យស្វែងរកវិធីកំចាត់យ៉ាងមានប្រសិទ្ធិភាព។ បើមិនមានវិធានការណ៍ ដែលមានចំណាយតិចនិងប្រសិទ្ធភាពចំពោះការរាតត្បាតនេះទេ ការបោះបង់ចោលដំណាំស្វាយចន្ទីនឹងបន្តកើនឡើង។ ឆ្នាំក្រោយ កសិករប្រមាណ ៤ ភាគរយ តាំងចិត្តថា នឹងមិនដាំដំណាំស្វាយចន្ទីទៀតទេ ហើយកសិករប្រហែល ១០ភាគរយ បានតាំងចិត្តនឹងឈប់ដាំដំណាំស្វាយចន្ទីក្នុងរយៈពេលពី ១-៥ឆ្នាំទៀត។

# ឯកសារយោង

Chan, V. (2007). *CAMBODIA'S EXPORT DIVERSIFICATION AND VALUE ADDITION*. PPT, Phnom Penh, Cambodia. Retrieved from http://www.eicambodia.org/events/upfile/EXPORT_DIVERSIFICATION_VALUEADDITION_by_Vuthy.pdf

Cheng, S. (2017, May 4). Cambodian farmers cash in on high cashew prices. *Phnom Penh Post*. Retrieved from http://www.phnompenhpost.com/business/cambodian-farmers-cash-high-cashew-prices

FAO. (2014). Major Food and Agriculture Commodities and Producers-Countries by Commodity. Retrieved November 1, 2017, from http://www.fao.org/faostat/en/#data/QC

IFC. (2010). *Prospects for Cambodia's Cashew Sub-sector*. Phnom Penh, Cambodia: International Finace Corporation.

Jostock, C. (1996). Cashew industry. In *Encycloperia of Latin American History and Culture* (Vol. 2). New York, USA.

Morton, J. F., & Dowling, C. F. (1987). *Fruits of warm climates*. Miami, FL : Winterville, N.C: J.F. Morton ; Distributed by Creative Resources Systems.

NIS. (2015). *Census of Agriculture in Cambodia 2013* (National Report on Final Census Results). Phnom Penh, Cambodia.

Padwe, J. (2011). Cashews, Cash and Capitalism in Northeast Cambodia. In *Cambodia's Economic Transformation* (pp. 110–136). United Kingdom: British Library Cataloguing in Publication Data.

Red River Food, Inc. (2011). *CASHEWS: highlights of the cashew industry*. Virginia, USA.

Sijisha, V. (2016). Top 5 Cashew Nut Producing Countries in the World. Retrieved November 2, 2017, from http://www.liveind.com/top-5-cashew-nut-producing-countries-in-the-world/11489

Wikiperdia. (2011). World's largest cashew tree. In *Maior cajueiro do mundo*. Retrieved from https://en.wikipedia.org/wiki/Maior_cajueiro_do_mundo

# បញ្ជីសំណួរសម្រាប់សំភាសន៍គ្រួសារ
# ដាំដំណាំស្វាយចន្ទី

ការណែនាំខ្លួន

*យើងខ្ញុំជាមន្ត្រីនៃអគ្គនាយកដ្ឋានកសិកម្ម ចុះមកសិក្សាស្វែងយល់ពីខ្សែសង្វាក់ផលិតកម្មដំណាំមួយចំនួនដូចជា ម្រេច ដំឡូងមី ពោតក្រហម និងស្វាយចន្ទីនៅតាមបណ្តាខេត្តមួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជា។ ការសិក្សាមានគោលបំណងស្វែងយល់ពីបញ្ហាប្រឈមមួយចំនួនរបស់អ្នកពាក់ព័ន្ធ ក៏ដូចជាកំណត់បាននូវដំណោះស្រាយសមស្របក្នុងការធានានូវផលិតកម្មដំណាំទាំងនោះប្រកបដោយនិរន្តរភាព ទាំងសេដ្ឋកិច្ច សង្គម និងបរិស្ថាន។*

សំគាល់

*សូមគូសរង្វង់ព័ទ្ធទៅលើចំលើយដែលត្រឹមត្រូវ*

## A. ព័ត៌មានសម្រាប់ត្រួតពិនិត្យ

| ១. ភារកិច្ច | ២. ថ្ងៃ ខែ ឆ្នាំ | ៣. ដោយអ្នកណា |
|---|---|---|
| ១. សំភាសន៍ | | |
| ២. ត្រួតពិនិត្យបញ្ជីសំណួរ | | |
| ៣. បញ្ចូលទិន្ន័យ | | |

## B. អត្តសញ្ញាណនៃគ្រួសារ

| | |
|---|---|
| ១.កូដ | ២.ឈ្មោះអ្នកដែលត្រូវសំភាសន៍ |
| ៣. ភេទ៖ ១ = ប្រុស ២ = ស្រី<br>៣.១ ចំនួនសមាជិកគ្រួសារ...............នាក់<br>៣.២ ស្រីសរុប................................នាក់<br>៣.៣ សមាជិកដែលមានអាយុចាប់ពី១៨ឆ្នាំឡើង.............................................នាក់ | ៤.កម្រិតសិក្សា៖ ១ = មិនចេះអាន ២ = បឋមសិក្សា<br>៣= អនុវិទ្យាល័យ ៤ = វិទ្យាល័យ<br>៥ = មហាវិទ្យាល័យ ៦. ផ្សេងៗ<br>(សូមញាក់)........................................................ |
| **៥. ទំនាក់ទំនងក្នុងគ្រួសាររបស់អ្នកឆ្លើយ៖**<br>១=ប្តី ២=ប្រពន្ធ ៣=កូន ៤=ផ្សេងៗ........... | ៦. លេខទូរស័ព្ទ....................................................... |

| | |
|---|---|
| ៧. ភូមិ | ៨. ឃុំ |
| ៩. ស្រុក | ១០. ខេត្ត |
| ១១. តើអ្នកជាអ្នករស់នៅទីនេះឬចំណូលថ្មី? ១. អ្នកស្រុកភូមិនេះ ២.អ្នកចំណូលថ្មី<br>១១.១ បើអ្នកចំណូលថ្មី តើអ្នករស់នៅខេត្តនេះ? ១. បាទ/ចាស ២. ទេ<br>១១.២ បើមកពីខេត្តផ្សេង តើខេត្តណា?......................................................................................<br>១១.៣ មករស់នៅទីនេះឆ្នាំណា? មកតាំងពីឆ្នាំ.................................................................................<br>១១.៤ ហេតុអ្វីបានផ្លាស់មក?.................................................................................................<br>.................................................................................................................................. | |
| ១២. តើមុខរបរសំខាន់របស់អ្នកមានអ្វីខ្លះ (អាចជ្រើសរើសច្រើន)?<br>១. ចម្ការ ២.ស្រែ ៣. លក់ដូរ ៤.លក់កម្លាំងពលកម្ម ៥.ផ្សេងៗ<br>(សូមបញ្ជាក់)................................................................................................................ | |

## C. ព័ត៌មានស្តីពីការងារដាំដុះ

### C1. ការដាំដុះ និងប្រមូលផល

| | |
|---|---|
| ១. តើអ្នកដាំស្វាយចន្ទីលើដីប៉ុន្មានកន្លែង?.............................................................................. | |
| ២. ផ្ទៃដីដាំដុះទី១៖.................................. ហត | ៣. តើអ្នកដាំប៉ុន្មានឆ្នាំហើយ?.............................ឆ្នាំ<br>៣.១ អ្នកពាក់ព័ន្ធ (ដាំដុះ ប្រមូលផល លក់) ប៉ុន្មាននាក់? .................នាក់<br>៣.២ ស្រី...................នាក់<br>៣.៣ អ្នកដែលមានអាយុក្រោម១៨ឆ្នាំ..........នាក់ |
| ៤. ដាំនៅខែណា? នៅខែ................................ | ៥. ប្រមូលផលខែណា? នៅខែ.............................. |
| ៦. ផ្ទៃដីប្រមូលផល .................................ហត | ៧. ទិន្នផលសរុប...........................គក្រ<br>៧.១តើវាជាទិន្នផលស្រស់ឬស្ងួត? ១.ស្រស់ ២.ស្ងួត |
| ៨.១. តម្លៃគ្រាប់ស្រស់/គ.ក្រ......................រៀល<br>៨.២. តម្លៃគ្រាប់ស្ងួត/គ.ក្រ........................រៀល | ៩.១ តម្លៃគ្រាប់ស្រស់ សរុប...........................រៀល<br>៩.២ តម្លៃគ្រាប់ស្ងួត សរុប.............................រៀល |
| ១០. ពូជ.............................................. | ១១. ប្រភពពូជ? បានមកពី................................ |

១២. ហេតុអ្វីជ្រើសរើសពូជនេះ? ដោយសារ.............................................................................................

១៣. បញ្ហាប្រឈមអ្វីខ្លះ?..........................................................................................................

.............................................................................................................................................

.............................................................................................................................................

១៤. តើអ្នកសង្កេតឃើញថាដីមានភាពប្រែប្រួលយ៉ាងណាទេ? ........................................................

.............................................................................................................................................

១៤.១ មានការហូរច្រោះដីឬទេ? ១.បាទ/ចាស ២.ទេ

១៤.១.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

១៤.២ ដីមានភាពហាប់ណែនជាងមុនឬទេ? ១. បាទ/ចាស ២. ទេ

១៤.២.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

១៤.៣ មានការកើនឡើងចំនួន និងប្រភេទស្មៅចង្រៃ? ១. បាទ/ចាស ២. ទេ

១៤.៣.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

១៤.៤ មានការកើនឡើងការរាតត្បាតនៃជំងឺ និងសត្វល្អិត ១. បាទ/ចាស ២. ទេ

១៤.៤.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

១៤.៥ ទិន្នផល ថយឬកើន? ១. កើន ២. ដដែល ៣.ថយ

១៤.៥.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

១៤.៦ ផ្សេងៗ សូមបញ្ជាក់...................................................................................................

.............................................................................................................................................

.............................................................................................................................................

| | |
|---|---|
| ១៥. ផ្ទៃដីដាំដុះទី២៖............................... ហត | ១៦. តើអ្នកដាំប៉ុន្មានឆ្នាំហើយ?.........................ឆ្នាំ<br>១៦.១ អ្នកពាក់ព័ន្ធ (ដាំដុះ ប្រមូលផល លក់) ប៉ុន្មាននាក់? .................នាក់<br>១៦.២ ស្រី.................នាក់<br>១៦.៣ អ្នកដែលមានអាយុក្រោម១៨ឆ្នាំ..........នាក់ |
| ១៧. ដាំនៅខែណា? នៅខែ........................... | ១៨. ប្រមូលផលខែណា? នៅខែ.......................... |
| ១៩. ផ្ទៃដីប្រមូលផល ...............................ហត | ២០. ទិន្នផលសរុប......................................គក្រ |

| | |
|---|---|
| | ២០.១ តើវាជាទិន្នផលស្រស់ឬស្ងួត?<br>១. ស្រស់ ២.ស្ងួត |
| ២១.១. តម្លៃគ្រាប់ស្រស់/គ.ក្រ....................រៀល<br>២១.២. តម្លៃគ្រាប់ស្ងួត/គ.ក្រ......................រៀល | ២២.១ តម្លៃគ្រាប់ស្រស់សរុប..........................រៀល<br>២២.២ តម្លៃគ្រាប់ស្ងួតសរុប............................រៀល |
| ២៣. ពូជ............................................... | ២៤. ប្រភពពូជ?បានមកពី.................................. |

២៥. ហេតុអ្វីជ្រើសរើសពូជនេះ? ដោយសារ.......................................................................................................

២៦. បញ្ហាប្រឈមអ្វីខ្លះ?..........................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

២៧. តើអ្នកសង្កេតឃើញថាដីមានភាពប្រែប្រួលយ៉ាងណាទេ? .......................................................................

.......................................................................................................................................................

២៧.១ មានការហូរច្រោះដី ឬទេ? ១. បាទ/ចាស ២. ទេ

២៧.១.១ កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

២៧.២ ដីមានភាពហាប់ណែនជាងមុនឬទេ? ១. បាទ/ចាស ២. ទេ

២៧.២.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

២៧.៣ មានការកើនឡើងចំនួន និងប្រភេទស្មៅចង្រៃ? ១. បាទ/ចាស ២. ទេ

២៧.៣.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

២៧.៤ មានការកើនឡើងការរាតត្បាតនៃជំងឺ និងសត្វល្អិត ១. បាទ/ចាស ២. ទេ

២៧.៤.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

២៧.៥ ទិន្នផលថយឬកើន? ១. កើន ២. ដដែល ៣.ថយ

២៧.៥.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

២៧.៦ ផ្សេងៗ សូមបញ្ជាក់.........................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

| | |
|---|---|
| ២៨. ផ្ទៃដីដាំដុះទី៣៖.............................. ហត | ២៩. តើអ្នកដាំប៉ុន្មានឆ្នាំហើយ?.......................ឆ្នាំ<br>២៩.១ អ្នកពាក់ព័ន្ធ (ដាំដុះ ប្រមូលផល លក់) ប៉ុន្មាននាក់? .....................នាក់<br>២៩.២ ស្រី.....................នាក់<br>២៩.៣ អ្នកដែលមានអាយុក្រោម១៨ឆ្នាំ..........នាក់ |
| ៣០. ដាំនៅខែណា? នៅខែ........................... | ៣១. ប្រមូលផលខែណា? នៅខែ........................ |
| ៣២. ផ្ទៃដីប្រមូលផល ..............................ហត | ៣៣. ទិន្នផលសរុប......................................គក្រ<br>៣៣.១តើវាជាទិន្នផលស្រស់ឬស្ងួត?<br>១. ស្រស់ ២.ស្ងួត |
| ៣៤.១. តម្លៃគ្រាប់ ស្រស់/គ.ក្រ..................រៀល<br>៣៤.២. តម្លៃគ្រាប់ស្ងួត/គ.ក្រ.....................រៀល | ៣៥.១ តម្លៃគ្រាប់ ស្រស់សរុប........................រៀល<br>៣៥.២ តម្លៃគ្រាប់ស្ងួត សរុប..........................រៀល |
| ៣៦. ពូជ............................................... | ៣៧. ប្រភពពូជ?បានមកពី............................... |

៣៨. ហេតុអ្វីជ្រើសរើសពូជនេះ? ដោយសារ....................................................................................

៣៩. បញ្ហាប្រឈមអ្វីខ្លះ?..........................................................................................................
..............................................................................................................................................
..............................................................................................................................................

៤០. តើអ្នកសង្កេតឃើញថាដីមានភាពប្រែប្រួលយ៉ាងណាទេ? ..........................................................
..............................................................................................................................................

៤០.១ មានការហូរច្រោះដី ឬទេ? ១. បាទ/ចាស ២. ទេ

៤០.១.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

៤០.២ ដីមានភាពហាប់ណែនជាងមុនឬទេ? ១. បាទ/ចាស ២. ទេ

៤០.២.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

៤០.៣ មានការកើនឡើងចំនួន និងប្រភេទស្មៅចង្រៃ?១. បាទ/ចាស ២. ទេ

៤០.៣.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

៤០.៤ មានការកើនឡើងការរាតត្បាតនៃជំងឺ និងសត្វល្អិត ១. បាទ/ចាស ២. ទេ

៤០.៤.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ

៤០.៥ ទិន្នផលថយឬកើន? ១. កើន ២. ដដែល ៣.ថយ

| |
|---|
| ៤០.៥.១កម្រិតណា? ១.ខ្លាំង ២.មធ្យម ៣.ខ្សោយ<br>៤០.៦ ផ្សេងៗ សូមបញ្ជាក់.............................................................<br>.............................................................<br>............................................................. |

C២. ចំណាយលើការដាំដុះ លើទំហំផ្ទៃដី....................................ហ.ត (តើអ្នកចំណាយអ្វីខ្លះសម្រាប់ការដាំដុះ? សូមរៀបរាប់នូវចំណាយរបស់អ្នកដែលមានក្នុងឆ្នាំកន្លងមកចាប់តាំងពីដាំរហូតដល់ប្រមូលផល និងលក់រួចរាល់)

| ចំណាយ | បរិមាណ | តម្លៃរាយ (រៀល) | សរុប (រៀល) |
|---|---|---|---|
| ១. ដើមពូជ (កំណាត់ដើម) | | | |
| ២. ដាក់ជីគីមី? ១. បាទ/ចាស ២. ទេ | | | |
| ៣. ជីធម្មជាតិ (គ.ក្រ) ១. បាទ/ចាស ២. ទេ | | | |
| ៤. ថ្នាំសំលាប់ស្មៅមុនដាំ (ល ឬ គ.ក្រ)<br>១. បាទ/ចាស ២. ទេ | | | |
| ៥. ថ្នាំសំលាប់ស្មៅក្រោយដាំ (ល ឬ គ.ក្រ)<br>១. បាទ/ចាស ២. ទេ | | | |
| ៦. ថ្នាំសំលាប់សត្វល្អិត ឬ ជំងឺ (ល ឬ គ.ក្រ)<br>១. បាទ/ចាស ២. ទេ | | | |
| ៧. ការរៀបចំដី ឬការភ្ជួររាស់ (ដង)<br>១. បាទ/ចាស ២. ទេ | | | |
| ៨. ការលើកពូនជារង (ដង)<br>១. បាទ/ចាស ២. ទេ | | | |
| ៩. ជួលកម្លាំងពលកម្មដាំដុះ (នាក់)<br>១. បាទ/ចាស ២. ទេ | | | |
| ១០. កម្លាំងពលកម្មជំរះស្មៅ (នាក់)<br>១. បាទ/ចាស ២. ទេ | | | |
| ១១. កម្លាំងពលកម្មប្រមូលផល (នាក់)<br>១. បាទ/ចាស ២. ទេ | | | |
| ១២. ជួលឧបករណ៍ឬគ្រឿងចក្រ (ដង)<br>១. បាទ/ចាស ២. ទេ | | | |

| | | | |
|---|---|---|---|
| ១៣. ដឹកជញ្ជូន និងទីផ្សារ (ដង)<br>១. បាទ/ចាស ២. ទេ | | | |
| ១៤. ជួលដី (មួយវគ្គដំណាំ ឬមួយឆ្នាំ)<br>១. បាទ/ចាស ២. ទេ | | | |
| ១៥. ផ្សេងៗ (សូមបញ្ជាក់)............................<br>........................................................................ | | | |

## C៣. និន្នាការក្នុងការដាំស្វាយចន្ទីនាពេលអនាគត

១. តើអ្នកដាំស្វាយចន្ទីនេះបានប៉ុន្មានឆ្នាំហើយ? ..............................ឆ្នាំ

២. តើអ្នកនិងបន្តរការដាំដុះនេះទៀតដែរឬទេនាឆ្នាំក្រោយៗ? ១.បាទ/ចាស ២. ទេ

២.១. បើបាទ/ចាស, តើអ្នកបន្តរដាំប៉ុន្មានឆ្នាំទៀត?...........................ឆ្នាំ

២.២ បើទេ, ហេតុអ្វីបានជាមិនបន្តរការដាំដុះ?........................................................................

..............................................................................................................................

## D. ទីផ្សារ

១.តើអ្នកលក់ស្វាយចន្ទីស្រស់នៅឯណា?.......................................................................................

១.១ ប៉ុន្មានគ.ក្រ.................................................................

១.២ ឈ្មោះអ្នកទិញ...........................................................

១.៣ ជនជាតិ៖ ១.ខ្មែរ ២.វៀតណាម ៣.ថៃ ៤.ចិន ៥.ផ្សេងៗ(បញ្ជាក់)..........................................

១.៤ លេខទូរស័ព្ទ.............................................................

១.៥ តើគេទិញនៅនិងកន្លែងឬដឹកទៅកន្លែងគេ? ១.នៅនឹងកន្លែង ២.ដឹកទៅកន្លែងគេ ៣.ផ្សេងៗ (បញ្ជាក់)..........................................................................................................................

..............................................................................................................................

២.តើអ្នកលក់ស្វាយចន្ទីស្ងួតនៅឯណា?.......................................................................................

២.១ ប៉ុន្មានគ.ក្រ.................................................................

២.២ ឈ្មោះអ្នកទិញ...........................................................

២.៣ ជនជាតិ៖ ១.ខ្មែរ ២.វៀតណាម ៣.ថៃ ៤.ចិន ៥.ផ្សេងៗ(បញ្ជាក់)..........................................

២.៤ លេខទូរស័ព្ទ.............................................................

១.៥ តើគេទិញនៅនិងកន្លែងយើងឬដឹកទៅកន្លែងគេ? ១.នៅនឹងកន្លែងយើង ២.ដឹកទៅកន្លែងគេ ៣.ផ្សេងៗ (បញ្ជាក់)..........................................................................................................................

..............................................................................................................................

៣. តើអ្នកលក់គ្រាប់ស្វាយចន្ទីស្រស់ និងស្ងួតតម្លៃប៉ុន្មាន? ចូរបំពេញតម្លៃក្នុងតារាងខាងក្រោមៈ

| ឆ្នាំ | ៣.១ គ្រាប់ស្រស់ (រៀល/គ.ក្រ) | ៣.២ គ្រាប់ស្ងួត (រៀល/គ.ក្រ) | ៣.៣ ផ្សេងៗ |
|---|---|---|---|
| ២០១៤ | | | |
| ២០១៥ | | | |
| ២០១៦ | | | |

សូមអរគុណ

# បញ្ជីសំណួរសម្រាប់ក្រុមពិភាក្សា

១. តើការដាំដុះដំណាំស្វាយចន្ទីមានបញ្ហាប្រឈមអ្វីខ្លះ?

| ឫសគល់នៃបញ្ហា? (ចាប់ពីមុនដាំរហូតដល់លក់ហើយ) | ហេតុអ្វីបានជាបញ្ហានេះកើតមានឡើង? | តើវាប៉ះពាល់អ្វីខ្លះ? | តើកន្លងមកអ្នកបានដោះស្រាយបញ្ហាទាំងនេះដូចម្តេច? | សំណើរសម្រាប់ដោះស្រាយ | តើអ្នកណាត្រូវដោះស្រាយបញ្ហានេះ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

២. តើប្រភេទពូជដំណាំស្វាយចន្ទីណាខ្លះ ដែលគេនិយមដាំដុះនៅទីនេះ? ចូររៀបរាប់ពីលក្ខណៈរបស់វា

| ប្រភេទលក្ខណៈរបស់ពូជ | ឈ្មោះពូជទី១ ............................... | ឈ្មោះពូជទី២ ............................... | ឈ្មោះពូជទី៣ ............................... |
|---|---|---|---|
| ហេតុអ្វី? | | | |
| ប្រវត្តិពូជ | | | |
| ទម្រង់ស្លឹក | | | |
| ពណ៌ជាង | | | |
| ពណ៌ដើម | | | |
| ពណ៌សំបកមើម | | | |

| | | | |
|---|---|---|---|
| ពណ៌សាច់មើម | | | |
| ធន់នឹងសមាសភាពចង្រៃ | | | |
| ធន់នឹងការប្រែប្រួលអាកាសធាតុ | | | |
| ឆ្លើយតបនឹងការប្រើប្រាស់ដី (ដីធម្មជាតិ/គីមី) | | | |
| ការគ្រប់គ្រងដំណាំ (ចូររៀបរាប់ពីការដាំដុះ ថែទាំ និងការប្រមូលផល) | | | |

៣. ចូររៀបរាប់ពីការដាំស្វាយចន្ទីដែលអ្នក ឬអ្នកភូមិបានដាំ? តើអ្នកសង្កេតឃើញមានការប្រែប្រួលទិន្នផលដែរឬទេ? ហេតុអ្វី?

| ការដាំដុះតាមដំណាក់កាលនីមួយៗ (ឧទាហរណ៍ការរៀបចំដី ការប្រើដី ការប្រើពូជ ការថែទាំ។ល។) | ការអង្កេតឃើញពីភាពប្រែប្រួល | មូលហេតុដែលធ្វើឱ្យមានការប្រែប្រួល |
|---|---|---|
| | | |
| | | |

| | | |
|---|---|---|
| | | |
| | | |
| | | |
| | | |

៤. តើអ្នក និងសមាជិកគ្រួសារធ្លាប់ចូលរួមការបណ្តុះបណ្តាលកសិកម្ម ដែរឬទេ? បើមាន ចូលរៀបរាប់

| ឈ្មោះវគ្គបណ្តុះបណ្តាល | តើវគ្គនេះនិយាយពីអ្វីខ្លះ? | រយៈពេល (ថ្ងៃ) | អ្នកចូលរួម | ការចាប់អារម្មណ៍ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

៥. និន្នាការក្នុងការទិន្នផលរយៈពេល៥ឆ្នាំកន្លងមក? តម្លៃរយៈពេល៥ឆ្នាំចុងក្រោយ ហេតុអ្វីឡើងចុះ?

៦. តើអ្នកមានសំណូមពរយ៉ាងណា ដើម្បីឱ្យការងារដាំដុះស្វាយចន្ទីមាននិរន្តរភាព ដោយធានាបាននូវចំណូលរបស់អ្នក ក៏ដូចជាថែរក្សាបាននូវធនធានបរិស្ថាន?